## គណៈកម្មាធិការដើម្បីការបោះឆ្នោត
## ដោយសេរី និងយុត្តិធម៌នៅកម្ពុជា

# របាយការណ៍សង្កេត
# លើការអនុវត្តកម្មវិធីនយោបាយ
## សំខាន់ៗមួយចំនួនរបស់រាជរដ្ឋាភិបាលកម្ពុជា

### រយៈពេល ៦ ខែដំបូង

### កក្កដា ២០០៤ — មករា ២០០៥

**របាយការណ៍លេខ I.3.1.1**

**មាតិកា** **ទំព័រ**


១. សិទ្ធិធ្វើបាតុកម្ម និងកូដកម្មដោយសន្តិវិធី ២
២. សង្គ្រាមប្រឆាំងអំពើពុករលួយ ៤
៣. កំណែទម្រង់ប្រព័ន្ធតុលាការ ៥
៤. ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ៦
៥. កំណែទម្រង់រដ្ឋបាលសាធារណៈ ៨
៦. នយោបាយការពារជាតិ និងសន្តិសុខ ១០
៧. កំណែទម្រង់ គ្រប់គ្រងដីធ្លី ១៣
៨. ចំណុចរសើបស្តីពីអាជីវកម្មលើផ្លូវជាតិលេខ៤ ១៤
៩. កំណើនការងារ ១៥
១០.វិស័យកសិកម្ម ១៧

**សន្និដ្ឋាន** **២២**

រាជរដ្ឋាភិបាលកម្ពុជានីតិកាលទី៣នៃរដ្ឋសភាបានកកើតឡើងនៅថ្ងៃទី១៥ កក្កដា ២០០៤ ហើយបានរំពឹងយក **យុទ្ធសាស្រ្តចតុកោណ** តាមបែប **"អភិបាលកិច្ចល្អជាស្នូល"** ដើម្បីអនុវត្ត **កម្មវិធីនយោបាយទាំង ៧៣** ចំណុចរបស់ខ្លួន ចំពោះមុខប្រជាពលរដ្ឋ ដែលបានបោះឆ្នោតឱ្យនៅថ្ងៃទី ២៧ កក្កដា ២០០៣។

ជាប្រចក្សភាពមួយដែលថា មានការថ្លែងនិងផ្តល់អនុសាសន៍ជាបន្តបន្ទាប់ទៀតពីសំណាក់ថ្នាក់ដឹកនាំរាជរដ្ឋាភិបាល និងរដ្ឋសភាថ្មីនេះ ដែលទំនងជាមានការប្តេជ្ញាចិត្តជាងអាណត្តិកន្លងទៅដូចជា កាលពីថ្ងៃទី ២០ សីហា ២០០៤ នៅក្នុង **វេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន** ដែលត្រូវបានរៀបចំឡើងក្នុងបំណងជំរុញការកាត់បន្ថយអំពើពុករលួយ និងការិយា-ធិបតេយ្យ សម្តេច **ហ៊ុន សែន** បានសង្កត់ធ្ងន់ថា *"កម្ពុជាគ្មានជម្រើសអ្វីប្រសើរជាងការបន្តជំរុញអនុវត្តដោយឥតរាថយនូវការកែទម្រង់ទាំងឡាយនេះទេ។ ជាមួយការប្តេជ្ញាបន្តកំណែទម្រង់យើងមានសំណាងអាចរស់៩០ភាគរយ។ បើយើងដកថយពីកំណែទម្រង់ យើងនឹងអាចមានសំណាងរស់រានមានជីវិតតែ១០ភាគរយប៉ុណ្ណោះ។"* ចំណែកសម្តេចក្រុមព្រះ **នរោត្តម រណឫទ្ធិ** ទ្រង់បានមានបន្ទូលកាលពីថ្ងៃទី២២ សីហា ២០០៤ ថា *"បញ្ហាយ៉ាងហោចណាស់ ៤ ដែលត្រូវដោះស្រាយពាក់ព័ន្ធនឹងកំណែទម្រង់រដ្ឋបាលសាធារណៈ ដើម្បីស្តារលទ្ធភាពទាក់ទាញវិនិយោគិនមកពីខាងក្រៅប្រទេស។ ទី១-គឺការលុបបំបាត់អំពើពុករលួយ ទី២-របៀបរបបការិយាធិបតេយ្យ ទី៣-ការពង្រឹងប្រព័ន្ធតុលាការ និងទី៤-ការធានានូវសន្តិសុខជាតិ។"*

យ៉ាងណាក៏ដោយ របាយការណ៍នេះផ្អែកលើការ**សិក្សាបែបសង្កេតឃ្លាំមើល** ភ្ជាប់ជាមួយ**ការវាយតម្លៃជាបឋម**ក្នុងរយៈពេល៦ខែដំបូងនេះ អំពី**ការអនុវត្តន៍នៃកម្មវិធីនយោបាយ**របស់រាជរដ្ឋាភិបាល ពិសេសលើការកែទម្រង់ផ្នែកសំខាន់ៗ និង**ការថ្លែងជាអនុសាសន៍**នានារបស់ថ្នាក់ដឹកនាំ។ របាយការណ៍នេះបានរកឃើញថា កំណែទម្រង់ផ្នែកសំខាន់ៗមួយចំនួនរបស់រាជរដ្ឋាភិបាល អ្វីដែលជាការសន្យានៅក្នុងកម្មវិធីនយោបាយ**៧៣ចំណុច នៅមិនទាន់ចាប់ផ្តើមអនុវត្តនៅឡើយ ជាភាគច្រើន** ប៉ុន្តែមានចំណុចអនុវត្តន៍បានសម្រេចតិចតួចខ្លះដែរដូចជា ការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ការតម្លើងប្រាក់បៀវត្សរ៍ឱ្យមន្ត្រីរាជការពី ១០ ទៅ ១៥% ជាដើម។

របាយការណ៍នេះ ផ្តល់នូវព័ត៌មានដែលរាជរដ្ឋាភិបាលបានអនុវត្តកម្មវិធីរបស់ខ្លួនក្នុងរយៈពេល៦ខែ គិតចាប់តាំងពីពេលកកើតមក។ ខាងក្រោមគឺជាចំណុចសំខាន់ៗ ដែលរបាយការណ៍រកឃើញថា មានកម្មវិធីល្អនៅលើក្រដាសរួមមានៈ

- **សិទ្ធិធ្វើបាតុកម្ម និងកូដកម្មដោយសន្តិវិធី**
- **ការប្រឆាំងអំពើពុករលួយ**
- **កំណែទម្រង់ប្រព័ន្ធតុលាការ**
- **ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**
- **កំណែទម្រង់រដ្ឋបាលសាធារណៈ**
- **នយោបាយការពារជាតិ និងសន្តិសុខ**
- **កំណែទម្រង់ គ្រប់គ្រងដីធ្លី**

- ការពិនិត្យកិច្ចសន្យាអាជីវកម្មលើផ្លូវជាតិលេខ ៤
- ការបង្កើនការងារ
- វិស័យកសិកម្ម

## ១_ សិទ្ធិធ្វើបាតុកម្ម និងកូដកម្មដោយសន្តិវិធី

ជាបន្តបន្ទាប់ អាជ្ញាធរមានសមត្ថកិច្ចបានបង្ក្រាប **និងរារាំងសកម្មភាពបាតុកម្ម** និងកូដកម្មដែលធ្វើឡើងដោយសន្តិវិធី បើទោះបីបញ្ហាជាកម្មវត្ថុទាមទារពាក់ព័ន្ធនឹងជីវភាពរស់នៅផ្ទាល់របស់ប្រជាពលរដ្ឋក៏ដោយ ។

និយាយឱ្យចំ គឺគ្មានការគោរពការសន្យាថ្មីៗ របស់រាជរដ្ឋាភិបាលកម្ពុជាដោយខ្លួនឯង នៅក្នុងកម្មវិធីនយោបាយ ចំណុចទី៨ ដែលបានបញ្ជាក់ថា: *"រាជរដ្ឋាភិបាលលើកទឹកចិត្តការអនុវត្តន៍សេរីភាពខាងសារព័ត៌មាន សេរីភាពខាងការបញ្ចេញមតិ សិទ្ធិធ្វើកូដកម្ម សិទ្ធិធ្វើបាតុកម្មដោយសន្តិវិធី និងសេរីភាពខាងការប្រជុំក្នុងក្របខ័ណ្ឌច្បាប់ និងបទបញ្ញត្តិជាធរមាន ដែលជាកត្តាជំរុញការអភិវឌ្ឍដោយសេរីនូវមនសិការ និងជំនឿនយោបាយរបស់សង្គម។"* ព្រមទាំងបានសំដែងឆន្ទៈថា *"នឹងធ្វើសេចក្តីព្រាងច្បាប់ស្តីពីបាតុកម្ម និងកូដកម្មឱ្យបានមុនដំណាច់ឆ្នាំ២០០៥ ដោយធ្វើការពិគ្រោះយោបល់ជាមួយមជ្ឈដ្ឋានពាក់ព័ន្ធនានា។"*

ដូចជាកាលពីថ្ងៃទី ៧ កញ្ញា ២០០៤ អាជ្ញាធរក្រុងភ្នំពេញ និងនគរបាលបានបង្ក្រាបការធ្វើកូដកម្មដោយ សន្តិវិធី ដែលជូនដំណឹង និងរៀបចំឡើងដោយ**ចលនានិស្សិតខ្មែរដើម្បីលទ្ធិប្រជាធិបតេយ្យ និងសមាគមអភិវឌ្ឍន៍ប្រជាជនអ្នកដឹកជញ្ជូនប្រជាធិបតេយ្យសេរីកម្ពុជា** ចំពោះការឡើងថ្លៃប្រេងសាំង ដោយពួកគេគ្រាន់តែជិះស៊ីក្លូតាមដងផ្លូវដើម្បីបង្ហាញពីឆន្ទៈរបស់ខ្លួន។ សេចក្តីប្រកាសរបស់សាលាក្រុងភ្នំពេញ បានបដិសេធមិនអនុញ្ញាតឱ្យមានការតវ៉ារបស់ក្រុមចលនានិស្សិតនោះទេ ដោយលើកសំអាងថា *"វាមិនមែនជាដំណោះស្រាយ[១]"*។

អង្គការសមាគមមិនមែនរដ្ឋាភិបាលសិទ្ធិមនុស្សជាតិ និងអន្តរជាតិ និងតំណាងពិសេសរបស់លោកអគ្គលេខាធិការ អង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំប្រទេសកម្ពុជា ធ្លាប់បានធ្វើការរិះគន់ថា *"ការជួបប្រជុំមួយចំនួនមិនត្រូវបានអនុញ្ញាតឡើយដោយសារមូលហេតុអំពីបញ្ហាសណ្តាប់ធ្នាប់សាធារណៈ និងបញ្ហាសន្តិសុខសង្គម តែអាជ្ញាធរមិនបានផ្តល់សេចក្តីបញ្ជាក់ឱ្យបានលម្អិតអំពីមូលហេតុនោះទេ។ មានករណីមួយចំនួនតូចដែលបាតុកម្មធ្វើឡើងដោយពុំមានការអនុញ្ញាតជាមុនត្រូវបានអាជ្ញាធរប្រើកម្លាំងហួសហេតុដើម្បីបំបែកហ្វូងបាតុករ[២]។"* មួយវិញទៀត *"ចំពោះការធ្វើបាតុកម្មអហិង្សាដែលធ្វើឡើងក្នុងគោលបំណងទាមទារនូវផលប្រយោជន៍ស្របច្បាប់របស់បាតុករត្រូវបានអាជ្ញាធរធ្វើការគំរាមកំហែង និងបង្ក្រាបយ៉ាងធ្ងន់ធ្ងរដោយប្រើអាវុធអាកា និងដំបងឆក់។ រាល់ការបង្ក្រាបយើងសង្កេតឃើញថា កម្លាំងប៉ូលីស និងកងរាជអាវុធហត្ថបំពាក់ដោយអាវុធហើយមានចំនួនពីរដងលើសចំនួនបាតុករ[៣]។"*

---

[១] កោះសន្តិភាព **"អាជ្ញាធរក្រុងព្រមានបាតុកម្មថ្ងៃនេះ វិបត្តិប្រេងសាំងឡើងថ្លៃបន្តបញ្ឆេះបញ្ហា"** លេខ ៥២១៩ ថ្ងៃទី៧ កញ្ញា ២០០៤។

[២] របាយការណ៍ របស់តំណាងពិសេសរបស់អគ្គលេខាធិការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា

[៣] សមាគមអាដហុក **"ស្ថានភាពសិទ្ធិមនុស្ស ២០០៤"** ខែ មករា ឆ្នាំ ២០០៥។

មានការវាយតម្លៃថា សេរីភាពនេះជួបប្រទះការរំលោភយ៉ាងធ្ងន់ធ្ងរពីសំណាក់អាជ្ញាធរដែលមានអំណាចគាំទ្រ ឬមិនគាំទ្រ ជាក់ស្តែងគណៈកម្មការប្រព្រឹត្តិកម្មនៃអង្គការ-សមាគមសិទ្ធិមនុស្សកម្ពុជា (CHRAC)បានរាយការណ៍ថាៈ ពីឆ្នាំ ២០០៣ រហូតដល់ខែតុលា ២០០៤ ករណីរំលោភអំពីសំណាក់អាជ្ញាធរមានសមត្ថកិច្ចមានដូចជា អាជ្ញាធរក្រុងភ្នំពេញ និងកងកម្លាំងប៉ូលីសទៅលើសិទ្ធិសេរីភាពជួបប្រជុំនិងធ្វើបាតុកម្មចំនួន **៣៥ករណី** ដែលរៀបចំឡើងដោយអង្គការ-សមាគមមិនមែនរដ្ឋាភិបាល កម្មកររោងចក្រកាត់ដេរសំលៀកបំពាក់ គណបក្សប្រឆាំង និស្សិត អាជីវករ ឬសូម្បីតែព្រះសង្ឃ។ ហើយនៅមុនការប្រជុំក្រុមម្ចាស់ជំនួយនៅខែធ្នូ ២០០៤នេះ អង្គការឃ្លាំមើលសិទ្ធិមនុស្សអន្តរជាតិ (Human Rights Watch) បានរិះគន់ថា *"អាជ្ញាធរកម្ពុជាបន្តហាមឃាត់ការធ្វើបាតុកម្មភាគច្រើន"*។ ជាពិសេស ដោយលើកឡើងពីបញ្ហារបស់ប្រជាពលរដ្ឋនៅតាមមូលដ្ឋាន អង្គការនេះឱ្យដឹងថា *"អ្នកភូមិជាច្រើនកាន់តែគ្មានលទ្ធភាពសំដែងមតិ និងការព្រួយបារម្ភរបស់ខ្លួនដោយសារតែនយោបាយរាជរដ្ឋាភិបាលរឹតបន្តឹងសេរីភាពជួបប្រជុំ។"*

មិនត្រឹមតែមិនបានអនុវត្តតាមកម្មវិធីនយោបាយដូចចំណុចទី៨ប៉ុណ្ណោះទេ ប៉ុន្តែអាជ្ញាធរមានសមត្ថកិច្ចថែមទាំងបិទសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិនិងសិទ្ធិក្នុងការជួបជុំគ្នានៅទីសាធារណៈដោយសន្តិវិធី និងឃាត់ខ្លួនបាតុករទៀតផង។ ការបំបិទសិទ្ធិសេរីភាពដូច្នេះ គឺជាការរំលោភដ៏ធ្ងន់ធ្ងរលើមាត្រា៣៧ និងមាត្រា៤១ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ និងមាត្រា១៩ មាត្រា២១ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយដែលប្រទេសកម្ពុជាជាហត្ថលេខីផងដែរ[៤]។

គួរឱ្យសោកស្តាយ ក្រុមប្រឹក្សាធម្មនុញ្ញបានធ្វើការបកស្រាយនិងផ្តល់ធម្មនុញ្ញភាពពេញលេញដល់ច្បាប់ស្តីពីបាតុកម្មឆ្នាំ១៩៩១ ដែលត្រូវបានគេមើលឃើញថាជាឧបករណ៍កាត់បន្ថយសិទ្ធិសេរីភាពបញ្ចេញមតិតាមរយៈការធ្វើបាតុកម្មសន្តិវិធីដ៏សំខាន់របស់ប្រជាពលរដ្ឋទូទៅ។ ការបកស្រាយហាក់ដូចជាមិនគាំទ្រសិទ្ធិសេរីភាពពេញលេញរបស់ប្រជាពលរដ្ឋបើពិនិត្យទៅលើស្មារតីរដ្ឋធម្មនុញ្ញ និងការអនុវត្តន៍ជាក់ស្តែងនៃច្បាប់ដែលមានស្រាប់។ មាត្រា៣៧ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាឆ្នាំ ១៩៩៣ ចែងថា *"សិទ្ធិធ្វើកូដកម្ម និងធ្វើបាតុកម្មដោយសន្តិវិធីត្រូវយកមកអនុវត្តនៅក្នុងក្របខ័ណ្ឌនៃច្បាប់"* និងមាត្រា៤១ ចែងថា *"ប្រជាពលរដ្ឋខ្មែរមានសេរីភាពខាងការបញ្ចេញមតិរបស់ខ្លួន សេរីភាពខាងសារពត៌មាន សេរីភាពខាងការបោះពុម្ពផ្សាយ សេរីភាពខាងការប្រជុំ"* ព្រមទាំងមាត្រា១៩ និង២១ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ ដែលជាការពិតមាត្រាទាំងនេះការពារនិងលើកស្ទួយសេរីភាពជាមូលដ្ឋានមួយនេះដល់ប្រជាពលរដ្ឋទូទៅជាអាទិភាព។ ប៉ុន្តែមាត្រាច្បាប់ស្តីពីបាតុកម្មឆ្នាំ១៩៩១ (មាត្រា ៣ វាក្យខណ្ឌ២: *"បើអាជ្ញាធរសាម៉ីយល់ឃើញថាបាតុកម្មមានលក្ខណៈដែលអាចនាំឱ្យកើតមានចលាចលនោះ អាជ្ញាធរសាម៉ីអាចហាមឃាត់បាតុកម្មដោយចេញសេចក្តីសំរេច..."*) បែរជាផ្តល់អំណាចអាទិភាពដល់ការសម្រេចរបស់អាជ្ញាធរសាធារណៈច្រើនទៅវិញ ដែលពេលខ្លះការសម្រេចចិត្តនេះរំលោភលើសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋ ពីព្រោះថាអាជ្ញាធរសម្រេចថាមិនឱ្យធ្វើបាតុកម្មដោយមិនបានពន្យល់មូលហេតុច្បាស់លាស់។

---

[៤] សេចក្តីប្រកាសពត៌មាន **"បាតុករ ៧ នាក់ត្រូវបានចាប់ខ្លួនដោយប៉ូលីសខ័ណ្ឌចំការមន"** ដោយគណៈកម្មាធិការប្រព្រឹត្តិកម្មនៃអង្គការ-សមាគមការពារសិទ្ធិមនុស្សកម្ពុជា ចុះថ្ងៃទី០៧ កញ្ញា ២០០៤។

## ២. សង្គ្រាមប្រឆាំងអំពើពុករលួយ

**មានការខិតខំនិយាយយ៉ាងសកម្មអំពីបញ្ហានៃការប្រឆាំងអំពើពុករលួយពីសំណាក់ថ្នាក់ដឹកនាំរាជរដ្ឋាភិបាល ប៉ុន្តែក្នុងរយៈពេល៦ខែនេះគ្មានសកម្មភាពអនុវត្តន៍ជាក់ស្តែងប្រឆាំងអ្នកប្រព្រឹត្តអំពើពុករលួយនៅឡើយ ។**

បន្ទាប់ពីការបង្កើតរាជរដ្ឋាភិបាលអាណត្តិទី ៣ ដែលមានឈ្មោះថាជា ***"រាជរដ្ឋាភិបាលអភិបាលកិច្ចល្អ"*** សម្តេចនាយករដ្ឋមន្ត្រី **ហ៊ុន សែន** បានប្រកាសចាប់ផ្តើម**"សង្គ្រាមប្រឆាំងនឹងអំពើពុករលួយ"**សម្រាប់អាណត្តិទី៣របស់ខ្លួន ចំនួន៣លើករួចមកហើយ ដែលលើកទី១ ធ្វើនៅកិច្ចប្រជុំគណៈរដ្ឋមន្ត្រីលើកទី១ ថ្ងៃទី១៦ កក្កដា ២០០៤ លើកទី២ នៅឯវេទិកាវិស័យឯកជននាថ្ងៃទី២០ សីហា ២០០៤ និងលើកទី៣ នៅឯកិច្ចប្រជុំត្រៀមរៀបចំមួយនាថ្ងៃទី១០ កញ្ញា ២០០៤ សម្រាប់កិច្ចប្រជុំក្រុមពិគ្រោះយោបល់ ។ គួររំលឹកផងដែរថា កម្មវិធីនយោបាយចំណុចទី១៥ត្រង់វាក្យខណ្ឌ "ការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ" បានលើកឡើងពីការ *"ជំរុញការអនុម័តច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ និងការបង្កើតស្ថាប័នឯករាជ្យអព្យាក្រឹត្យមួយសំរាប់ប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយឱ្យបានក្នុងឆ្នាំ២០០៥។"*

ជាការពិត រាជរដ្ឋាភិបាលក្នុងរយៈពេលពីរអាណត្តិកន្លងមកបានខកខានរៀបចំស្ថាបនាបន្តរចនាសម្ព័ន្ធមូលដ្ឋាន ទាំងផ្នែកគតិយុត្តិ និងទាំងយន្តការក្នុងការប្រឆាំងនឹងអំពើពុករលួយនេះ ។ ប៉ុន្តែរហូតមកដល់ពេលនេះ គេកត់សម្គាល់មិនឃើញមានការអនុម័តច្បាប់ និងការរៀបចំស្ថាប័ន ឬការប្រឆាំងជាក់ស្តែង ចំពោះអំពើពុករលួយនេះនៅឡើយទេ។ សង្គ្រាមប្រឆាំងនឹងអំពើពុករលួយចាំបាច់ឱ្យមានឆន្ទៈនយោបាយច្បាស់លាស់ និងមធ្យោបាយគ្រប់គ្រាន់ **សម្រាប់ការប្រឆាំងនឹងអំពើពុករលួយនេះ ។** បើទោះបីពុំទាន់មានច្បាប់ប្រឆាំងអំពើពុករលួយយ៉ាងណាក៏ដោយ ក៏រាជរដ្ឋាភិបាលអាចចាប់ផ្តើមជាបន្ទាន់ប្រឆាំងអំពើពុករលួយ ព្រោះថាខណៈនេះមានមាត្រា៤៨ នៃបទបញ្ញត្តិស្តីពីប្រព័ន្ធតុលាការច្បាប់ព្រហ្មទណ្ឌ និង**នីតិវិធីព្រហ្មទណ្ឌសំរាប់ការអនុវត្តន៍នៅប្រទេសកម្ពុជាក្នុងសម័យអន្តរកាល ( អ៊ុនតាក់) ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ១៩៩២** ដែលចែងពីអំពើសូកប៉ាន់និងជាមាត្រាច្បាប់ជាធរមានដែលពាក់ព័ន្ធនឹងអំពើពុករលួយ ។ ដើម្បីបង្ហាញពីការប្តេជ្ញាចិត្តចំពោះបញ្ហានេះ រាជរដ្ឋាភិបាលត្រូវតែបង្ហាញនូវឧទាហរណ៍នានានៃវិធានការជាក់ស្តែង ប្រឆាំងនឹងអំពើពុករលួយដូចជា យ៉ាងហោចណាស់ទៅលើករណីចំនួន ២ ដែលបានកើតឡើងរួចទៅហើយក្នុងនោះរួមមាន ការរកឃើញពីការប្រើប្រាស់មូលនិធិមិនត្រឹមត្រូវ និងអាចជាប់ពាក់ព័ន្ធនឹងអំពើពុករលួយនូវទឹកប្រាក់ចំនួន ២,៨ លានដុល្លារអាមេរិក របស់មន្ត្រីរាជរដ្ឋាភិបាលក្នុងកម្មវិធីដោះស្រាយជីវភាពដល់កងទ័ពដែលត្រូវកាត់រំសាយ ដែលឧបត្ថម្ភឡើងដោយធនាគារពិភពលោក និងការគិបកេងបន្លំពាក់ព័ន្ធជាមួយមន្ត្រីរាជរដ្ឋាភិបាល ក្នុងគំរោងស្បៀងពលកម្មដែលគិតជាទឹកប្រាក់ប្រមាណ២លានដុល្លារអាមេរិកដែលឧបត្ថម្ភដោយអង្គការស្បៀងអាហារពិភពលោក ។

**សូមអបអរសាទរចំពោះក្រសួងទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច** ដែលបានលើកយក និងចាប់**ផ្តើមពិភាក្សាសេចក្តីព្រាងច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ ។**

បច្ចុប្បន្ន សេចក្តីព្រាងច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយដែលមានការចូលរួមពីសំណាក់អង្គការមិនមែនរដ្ឋាភិបាលមួយចំនួនផងដែរនោះ កំពុងស្ថិតនៅក្នុងការពិភាក្សាបន្ទាប់ពីការបញ្ជូនត្រលប់ពីរដ្ឋសភាដើម្បីធ្វើការកែប្រែ ។

## ៣. កំណែទម្រង់ប្រព័ន្ធតុលាការ

ការសង្កេតក្នុងរយៈពេល៦ខែចាប់ពីការបង្កើតរាជរដ្ឋាភិបាលអាណត្តិទី៣មកបានបង្ហាញថា ការកែទម្រង់ប្រព័ន្ធតុលាការពុំទាន់បានចាប់កំរើកអនុវត្ត ដែលជាតំរុយនៃកំណែទម្រង់នេះនៅឡើយ ក្រៅអំពីការចាប់ផ្តើមគំនិតមួយចំនួនជាមួយនឹងការជួយជំរុញពីអង្គការសហប្រជាជាតិក្នុងការឈានទៅរកការកាត់សេចក្តីមេដឹកនាំខ្មែរក្រហម និងការរៀបចំផែនការសកម្មភាពរយៈពេលវែង និងខ្លីតែប៉ុណ្ណោះ។ នៅចំណុចទី ១៥ ស្តីពីកំណែទម្រង់ប្រព័ន្ធតុលាការក្នុងចំណោមកម្មវិធីទាំង៧៣ចំណុចវិញ របាយការណ៍បានកត់សម្គាល់ឃើញថា មានចំណុចសន្យាជាច្រើនដែលនៅក្នុងនោះរាជរដ្ឋាភិបាលត្រូវសម្រេចឱ្យបាននៅអាណត្តិទី៣ដូចជាៈ ការធ្វើឱ្យ *"មានជំនឿទុកចិត្តពីមជ្ឈដ្ឋានជាតិ និងអន្តរជាតិលើប្រព័ន្ធតុលាការកម្ពុជា ការពង្រឹងនីតិរដ្ឋ លុបបំបាត់វប្បធម៌និទណ្ឌភាព បញ្ចប់ការតាក់តែងច្បាប់លក្ខន្តិកៈចៅក្រម ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ក្រម និងនីតិវិធីព្រហ្មទណ្ឌ ក្រម និងនីតិវិធីរដ្ឋប្បវេណី ច្បាប់ដំណើរការសារការី និង អាជ្ញាសាលា ការបង្កើតតុលាការពាណិជ្ជកម្ម តុលាការអនីតិជន តុលាការការងារ តុលាការរដ្ឋបាល ការដាក់ឱ្យចូលនិវត្តន៍ ចៅក្រមដែលមានអាយុចាប់ពី៦០ឆ្នាំឡើង ការបណ្តុះបណ្តាលចៅក្រម ការបង្កើតសាលា និងបណ្តុះបណ្តាលក្រឡាបញ្ជី អាជ្ញាសាលា សារការី និងនគរបាលយុត្តិធម៌។"*

ការកែទម្រង់ប្រព័ន្ធតុលាការនេះត្រូវបានលើកឡើងថាជាបញ្ហាសំខាន់តាំងពីអាណត្តិនៃរាជរដ្ឋាភិបាលមុនមកម្ល៉េះ ហើយដែលបញ្ហានេះតែងត្រូវបានលើកឡើងថា ជាបញ្ហារន្ធើនមួយពីគ្រប់ស្ថាប័នជាតិ និង អន្តរជាតិ។ ក្រុមម្ចាស់ជំនួយនៅឯកិច្ចប្រជុំក្រុមពិគ្រោះយោបល់លើកទី៧ អង្គការមិនមែនរដ្ឋាភិបាល ធនាគារពិភពលោក នៅក្នុងរបាយការណ៍ "**កម្ពុជាលើផ្លូវបំបែក**" មើលឃើញថា កំណែទម្រង់ជាទូទៅមានលក្ខណៈយឺតយ៉ាវ។ កន្លងមកអាណត្តិមុននេះ គេឃើញមានការអនុវត្តន៍ការកែទម្រង់ខ្លះ ដូចជាការបណ្តុះបណ្តាលចៅក្រម ការរៀបចំប្រាក់បៀវត្សរ៍ចៅក្រម ការរៀបចំសេចក្តីព្រាងក្រម និងនីតិវិធីព្រហ្មទណ្ឌ ហើយនិងក្រម និងនីតិវិធីរដ្ឋប្បវេណី។

ចំណែកឯការកសាងជំនឿទុកចិត្តលើប្រព័ន្ធតុលាការ និងការលុបបំបាត់វប្បធម៌និទណ្ឌភាព មតិសាធារណជនមួយចំនួនធំ រួមទាំងម្ចាស់ជំនួយ និងអង្គការមិនមែនរដ្ឋាភិបាលមួយចំនួនបានបន្តបញ្ជាក់ថា **ប្រព័ន្ធតុលាការនៅកម្ពុជាមិនឯករាជ្យ ពុករលួយ និងមានភាពលម្អៀង** ដូចប្រសាសន៍ថ្មីៗនេះរបស់លោក **ធន សារាយ** ប្រធានសមាគមអាដហុកបានឱ្យដឹងថា *"...ក្នុងឆ្នាំ២០០៤...យើងសង្កេតឃើញថា មានចាប់តែអ្នកក្រ និងអ្នកគ្មានអំណាច តែចំណែកអ្នកមានអំណាច អ្នកមានលុយកម្រនឹងឃើញមាន និងគ្មានទាល់តែសោះនៅឆ្នាំ២០០៤ ដែលត្រូវបានតុលាការឃាត់ខ្លួនទោះបីអ្នកនោះរំលោភបំពានលើដីរបស់អ្នកដទៃ ឬដីរដ្ឋក្តីមិនត្រូវបានតុលាការហ៊ាន ឬមានសេចក្តីក្លាហានចេញដីកាឃាត់ខ្លួន ចាប់ខ្លួនគេទេ បានតែអ្នកក្រ និងអ្នកគ្មានអំណាចនោះឯង។"* ហើយអនុសាសន៍មួយនៅក្នុងសេចក្តីថ្លែងការណ៍របស់អង្គការមិនមែនរដ្ឋាភិបាលចំពោះកិច្ចប្រជុំក្រុមពិគ្រោះយោបល់លើកទី៧ នៅចុងឆ្នាំ ២០០៤ កន្លងទៅ ក៏បានបង្ហាញពីការព្រួយបារម្ភអំពីអព្យាក្រឹត្យភាពខាងនយោបាយរបស់តុលាការ ថាតើ *"ត្រូវមានច្បាប់ណាមួយដើម្បីធានាថា ស្ថាប័នតុលាការមិនមានការពាក់ព័ន្ធគណបក្សនយោបាយ។"*

កំណែទម្រង់ប្រព័ន្ធតុលាការនេះជាការចាំបាច់ និងជាការងារមូលដ្ឋានគ្រឹះមួយសំរាប់កំណែទម្រង់ផ្សេងៗទៀតរបស់រាជរដ្ឋាភិបាល ដែលចូលរួមដោយផ្ទាល់ក្នុងការស្ថាបនានីតិរដ្ឋ។ ស្ថាប័នពាក់ព័ន្ធជាពិសេសរាជរដ្ឋាភិបាលអាណត្តិទី៣នេះ **គួរចាប់កំរើកអនុវត្តន៏ឡើងក្នុងការកែទម្រង់ប្រព័ន្ធតុលាការនេះ** ព្រោះជាលទ្ធផលវានឹងមិនត្រឹមតែផ្តល់ភាពយុត្តិធម៌ដល់ប្រជាពលរដ្ឋ និងបន្ថយការរំលោភសិទ្ធិមនុស្សតែប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងនឹងផ្តល់បរិយាកាសជាប្រព័ន្ធគតិយុត្តិជឿទុកចិត្តមួយដែលសម្រួល និងលើកទឹកចិត្តដល់វិនិយោគិននៃវិស័យឯកជនឱ្យចូលរួមចំណែកដោយពេញលេញ ដោយយុត្តិធម៌ស្របច្បាប់ និងដោយការពេញចិត្តចំពោះការអភិវឌ្ឍសេដ្ឋកិច្ចប្រទេស។

## ៤~ ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

ចំពោះការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈវិញ គឺបាននិងកំពុងដំណើរការក្នុងស្ថានភាពដដែលៗ ដូចអាណត្តិមុនហើយពុំទាន់មានការអនុវត្តន៏ណាប្រែប្រួលធំដុំលើកម្មវិធីនយោបាយនោះទេ បើទោះជានៅចុងឆ្នាំ២០០៤មានឯកសារផែនការសកម្មភាព ស្តីពីការកែទម្រង់នៃកម្មវិធីគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងមានបង្កើនចំនួនគម្រោងថវិកាជាតិ ឆ្នាំ ២០០៥ក៏ដោយ។ ការសង្កេតពុំទាន់ឃើញការអនុវត្តន៏ចំណុចទី៣៣និង៣៤នៃកម្មវិធីនយោបាយ៧៣ចំណុចជាក់ស្តែងនៅឡើយ។ ចំណុចនោះមានដូចជា *"ការប្រកាន់ខ្ជាប់នូវវិន័យក្នុងការគ្រប់គ្រងថវិកា... បន្តខិតខំពង្រឹងការប្រមូលចំណូលគ្រប់ប្រភេទទាំងចំណូលពន្ធដារ។ ...ទាំងចំណូលមិនមែនពន្ធដារ ការអនុវត្តន៍យ៉ាងហ្មត់ចត់នូវច្បាប់ស្តីពីសារពើពន្ធ ការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ...ការបន្តអនុវត្តវប្បធម៌គ្មានការលើកលែងពន្ធ ការពង្រីកមូលដ្ឋានពន្ធដារ ការពង្រឹងសមត្ថភាពរបស់រដ្ឋបាលពន្ធដារ និងរបស់រដ្ឋបាលគយនិងរដ្ឋាករ និងការធានាគ្រប់គ្រងដោយត្រឹមត្រូវនិងហ្មត់ម៉ត់ចត់នូវទ្រព្យសម្បត្តិគ្រប់ប្រភេទរបស់រដ្ឋ រួមទាំងទ្រព្យសម្បត្តិរូបិយទាំងទ្រព្យសម្បត្តិអរូបិយ... ជំរុញដំណើរការឯកជនភាវូបនីយកម្ម...រៀបចំសេចក្តីព្រាងច្បាប់គ្រប់គ្រងកាស៊ីណូ...ពង្រឹងយន្តការសវនកម្ម និងកិច្ចការលទ្ធកម្មសាធារណៈដោយផ្តល់អាទិភាពខ្ពស់លើចំណាយវិស័យសង្គមកិច្ច សេដ្ឋកិច្ច និងការវិនិយោគសាធារណៈ...ពង្រឹងប្រព័ន្ធធនាគារក្នុងប្រទេស...លើកស្ទួយវិស័យឥណទានជនបទ ដើម្បីជួយផ្តល់សេវាហិរញ្ញវត្ថុនិងប្រាក់កម្ចីដែលមានការប្រាក់ទាបបំផុត...។"*

ការសង្កេតខាងក្រោមនេះរកឃើញថា ចំពោះថវិកាជាតិឆ្នាំ២០០៥ មានការបង្កើនចំនួនគម្រោងថវិកាជាតិរហូតដល់៧៩២លានដុល្លារអាមេរិក បើប្រៀបធៀបនឹងឆ្នាំ២០០៤ ដែលមានត្រឹមតែ ៧៥២លានដុល្លារអាមេរិក ប៉ុន្តែស្ថានភាព**គឺគ្មានតុល្យភាពរួមរវាងចំណូលនិងចំណាយជាតិ**។ បរិមាណអតុល្យភាពនេះ មានជាមធ្យមប្រមាណ ១៩០,៥ លានដុល្លារអាមេរិកពីឆ្នាំ១៩៩៧ ដល់២០០៣[៥]។ ហើយបើយោងតាមការគណនាតុល្យភាពនៃថវិកាទូទៅរបស់រដ្ឋនៅក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ២០០៥ ឃើញថាឱនភាពសរុបនៃថវិកាទូទៅមានអត្រា ២៥% នៃបរិមាណសរុប ចំណាយថវិកាដែលបរិមាណនេះនឹងត្រូវបំពេញទាំងស្រុងដោយហិរញ្ញប្បទានក្រៅប្រទេស។ ជាសំណាងល្អដែលប្រទេសកម្ពុជានៅតែទទួលបានជំនួយបរទេសសំរាប់បំពេញកង្វះខាតនេះ ប៉ុន្តែគេរំពឹងថា តាមរយៈកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នឹងជួយដល់ការបង្កើនខ្ចង់ចំណូលថវិកាជាតិមួយ ដែលមានលក្ខណៈឯករាជ្យពីជំនួយបរទេស។

[៥] ប្រភព: វិទ្យាស្ថានជាតិស្ថិតិ សៀវភៅស្ថិតិឆ្នាំ ២០០៣ របាយការណ៍ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរបាយការណ៍មូលនិធិរូបិយវត្ថុអន្តរជាតិ។

ថវិកាឆ្នាំ២០០៥ មានគោលដៅបង្កើនចំណូលក្នុងស្រុកស្មើនឹង១២,១៧%នៃផលិតផលក្នុងស្រុកសរុប(ផសស) ដែលនៅខណៈនេះប្រាក់ចំណូលបច្ចុប្បន្នមានត្រឹមតែ១០%នៃផ.ស.សប៉ុណ្ណោះ ហើយមិនអាចប្រៀបធៀបបានទៅនឹងកម្រិតចំណូលជាមធ្យមរបស់បណ្ដាប្រទេសកំពុងអភិវឌ្ឍន៍ដែលមានចំនួន១៦%នៃផ.ស.ស។ ដោយមើលឃើញបញ្ហានេះ ធនាគារពិភព-លោក ក៏បានផ្ដល់អនុសាសន៍ផងដែរថា *"រាជរដ្ឋាភិបាលថ្មីត្រូវតែពិចារណា សាកល្បងកែប្រែដ៏ធំមួយ លើការផ្ដល់ការលើកទឹកចិត្ត និងការគ្រប់គ្រងការអនុវត្តន៍នៅក្នុងនាយកដ្ឋានពន្ធដារនិងគយ។...ហើយកំណែលំអបែបនេះមិនគួររង់ចាំរហូតដល់មានការកែទំរង់សេវាស៊ីវិលដ៏ធំមួយនោះទេ។ ប្រសិនបើគ្មានការធ្វើឱ្យប្រសើរឡើងវិញយ៉ាងខ្លាំងក្លាលើរដ្ឋបាលពន្ធដារទេ ទស្សនៈវិស័យលើកំណើនកំពុងថយចុះនឹងមិនអាចមានលក្ខណៈប្រសើរឡើយ[៦] ។"* ម្យ៉ាងទៀត ឱនភាពថវិកាខាងលើដែលមានជារៀងរាល់ឆ្នាំអាចនិយាយបានថា ត្រូវបានដាក់ទំងន់ដោយការចំណាយខ្ជះខ្ជាយមិនចំគោលដៅរបស់រាជរដ្ឋាភិបាលកន្លងមកដូចជា ការបង្កើតក្រសួង ស្ថាប័ន គណៈកម្មាធិការបន្ថែមនានា ដែលមិនចាំបាច់ហើយគ្មានប្រសិទ្ធភាពការងារ និងការបង្កើន សមាជិករាជរដ្ឋាភិបាលដ៏ច្រើន ពិសេសនៅអាណត្តិទី៣នេះ ។

ដូចដែលធនាគារពិភពលោកនៅក្នុងរបាយការណ៍របស់ខ្លួនបានរិះគន់ថា *"មានចំណុចខ្សោយធ្ងន់ធ្ងរមួយចំនួននៅក្នុងការអនុវត្តន៍* ដោយបានយោងទៅដល់កង្វះការត្រួតពិនិត្យមានប្រសិទ្ធភាពពី *រដ្ឋសភាជាតិលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងអវត្តមាន យន្តការដែលមានប្រសិទ្ធភាពណាមួយរបស់ប្រជាពលរដ្ឋដើម្បីទាមទារការត្រួតពិនិត្យបែបនេះ។"* របាយការណ៍បានបន្តទៀតថាៈ *"ការត្រួតពិនិត្យផ្ទៃក្នុងនិងផ្ទៃក្រៅដែលមានលក្ខណៈទន់ខ្សោយនាំឱ្យមានប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈមួយដែលអាច និងពិតជាមានការរំលោភបំពាន។ ទាំងអស់នេះមានន័យថា ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈស្ថិតនៅឆ្ងាយពីគោលបំណងរំពឹងទុកនៅក្នុងការប្រយុទ្ធប្រឆាំងនឹងភាពក្រីក្រ[៧] ។"*

**មកដល់ពេលនេះ គ្មានការពិចារណាណាមួយទៅសេចក្ដីព្រាងច្បាប់កាស៊ីណូនៅឡើយ ។**

ក្នុងអំឡុងពេលនេះ សកម្មភាពដកហើយផ្លាស់ប្ដូរតំណែងមន្ត្រីដឹកនាំនាយកដ្ឋានពន្ធដារគ្រាន់តែជាការផ្លាស់ប្ដូរមន្ត្រីដែលខ្វះសមត្ថភាពដឹកនាំ ហើយបានកាន់តំណែងជាយូរមកហើយ( ជាង២០ឆ្នាំ) ។ គេនៅមានមន្ទិលថាតើវិធានការរបស់ប្រមុខរាជរដ្ឋាភិបាលក្នុងបំណងលុបបំបាត់អំពើពុករលួយបែបនេះនឹងបន្តទៅមុខទៀតឬយ៉ាងណា ហើយតើអាចធ្វើទៅលើមន្ត្រីធំៗនៃរាជរដ្ឋាភិបាលដែរឬទេ ក្នុងករណីរកឃើញកំហុសកេងប្រវ័ញ្ច ឬធ្វើឱ្យបាត់បង់ថវិកាជាតិដូច្នេះ? រាជរដ្ឋាភិបាល ***"គួរមិនត្រឹមតែមិនសម្រួចឈើពុក ប៉ុន្តែថែមទាំងកុំប្រើឈើពុកតែម្ដង"*** ដើម្បីធ្វើឱ្យប្រសើរឡើងនូវការបង្កើនចំណូល និងគ្រប់គ្រងចំណាយថវិកាជាតិឱ្យមានតម្លាភាព និងគណនេយ្យភាព និងឈានដល់ការកែទម្រង់ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈមួយដែលមានគុណភាព និងប្រសិទ្ធភាពជារួម ។

[៦] "កម្ពុជាលើផ្លូវបំបែក" របាយការណ៍ធនាគារពិភពលោក ថ្ងៃទី ១៥ តុលា ២០០៤ ទំព័រ ២៦ ។

[៧] "កម្ពុជាលើផ្លូវបំបែក" របាយការណ៍ធនាគារពិភពលោក ថ្ងៃទី ១៥ តុលា ២០០៤ ទំព័រ ៦២ ។

## ៥. កំណែទម្រង់រដ្ឋបាលសាធារណៈ

របាយការណ៍នេះបានសង្កេតឃើញថា**ពុំទាន់មានការអនុវត្តន៍កម្មវិធីនយោបាយពាក់ព័ន្ធទៅនឹងកំណែទំរង់រដ្ឋបាលសាធារណៈបានធំដុំនៅឡើយ មិនតែប៉ុណ្ណោះថែមទាំងបន្តការបង្កើនកម្រាស់ការិយាធិបតេយ្យខាងនយោបាយទៀផង។** ការអនុវត្តកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលទៅលើចំណុចចំនួនតិចតួច ប៉ុន្តែស្ទើរទាំងអស់មានការស្រពិចស្រពិលក្នុងការចាប់ផ្តើម។ ក្នុងចំណុចទី១៥ ដែលផ្តោតលើការពង្រឹងសេវាសាធារណៈនោះ ក្រសួងមហាផ្ទៃ និងស្មៀនឃុំ/សង្កាត់បាននិងកំពុងអនុវត្តការចុះអត្រានុកូលដ្ឋាន និងការផ្តល់លិខិតអនុញ្ញាតផ្សេងៗ ប័ណ្ណកម្មសិទ្ធិដីធ្លីដែលមានភាពយឺតយ៉ាវ។ យោងតាមថវិកាជាតិឆ្នាំ២០០៥ ប្រាក់បៀវត្សរ៍មន្ត្រីរាជការត្រូវបានតម្លើងរវាង១០ទៅ១៥% ប៉ុន្តែការអនុវត្តន៍វិស័យអាទិភាពផ្សេងៗទៀត គឺមានភាពដូចគ្នាទៅនឹងឆ្នាំកន្លងទៅដូចជា សេវាពាក់ព័ន្ធនឹងការវិនិយោគ សេវាមូលដ្ឋាន (អប់រំ និងសុខាភិបាល) សេវាពាក់ព័ន្ធនឹងចំណូលចំណាយរដ្ឋ។ ហើយ *"នីតិវិធីនៃការទទួលសេវាសាធារណៈនឹងត្រូវសំរួល និងធ្វើឱ្យមានភាពសាមញ្ញតាមរយៈការលុបបំបាត់នូវការងារដែលជាន់គ្នា ការកាត់បន្ថយការិយាធិបតេយ្យ... បច្ចេកទេសវិមជ្ឈការថ្នាក់ឃុំ/សង្កាត់ យន្តការច្រកចេញ-ចូលតែមួយ ព្រមទាំងបង្កើតការិយាល័យប្រជាពលរដ្ឋ* ក៏មិនមានការផ្លាស់ប្តូរតាមការដាក់ទិសដៅសម្រាប់ការផ្លាស់ប្តូរទំនាក់ទំនងរដ្ឋ និងប្រជាពលរដ្ឋពី *"អ្នកគ្រប់គ្រង និងអ្នកដែលត្រូវគេគ្រប់គ្រង" ទៅជា "អ្នកផ្តល់សេវា និងអ្នកប្រើប្រាស់សេវា* នៅឡើយ[៨]"។

ប៉ុន្តែ រឿងនេះមានការបញ្ចេញសារគាំទ្រពីថ្នាក់ដឹកនាំដូចជា **សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ** បានមានព្រះបន្ទូលកាលពីថ្ងៃទី២២ សីហា ២០០៤ ថា *"បញ្ហាយ៉ាងហោចណាស់ ៤ ដែលត្រូវដោះស្រាយពាក់ព័ន្ធនឹងកំណែទម្រង់រដ្ឋបាលសាធារណៈ ដើម្បីស្តារលទ្ធភាពទាក់ទាញវិនិយោគិនមកពីខាងក្រៅប្រទេស។ ទី១-គឺការលុបបំបាត់អំពើពុករលួយ ទី២-របៀបរបបការិយាធិបតេយ្យ ទី៣-ការពង្រឹងប្រព័ន្ធតុលាការ និង ទី៤-ការធានានូវសន្តិសុខជាតិ។"*

ទោះបីបញ្ហាពាក់ព័ន្ធនឹងការវិនិយោគនេះ ត្រូវបានលើកឡើងចំៗពីសំណាក់តួអង្គវិស័យឯកជន និងរាជរដ្ឋាភិបាល ក៏ការដោះស្រាយពុំមានប្រសិទ្ធភាពតាំងពីវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជនលើកទី១មកម្ល៉េះ។ ជាក់ស្តែង**របាយការណ៍របស់ធនាគារពិភពលោក**ចេញនៅថ្ងៃទី១២ សីហា ២០០៤ ស្តីពីបរិយាកាសនៃការបណ្តាក់ទុននៅព្រះរាជាណាចក្រកម្ពុជាបានបញ្ជាក់ថា: *"៤ ភាគ ៥ នៃក្រុមហ៊ុនឯកជន ៨០០ ដែលកំពុងរកស៊ីនៅក្នុងប្រទេសកម្ពុជាបានទទួលស្គាល់ថា គឺជាការចាំបាច់ណាស់ក្នុងការសូកដើម្បីអាចរកស៊ីបាន។"* ពិសេសទៀតនៅថ្ងៃទី១៧ សីហា ២០០៤ **ព្រះមហាវីរក្សត្រ** ព្រះអង្គក៏មានព្រះរាជចំណារលើអត្ថបទកាសែតបារាំងកាំបូដស័រថា: *"...រឿងសូកប៉ាន់វិញ ប្រទេសកម្ពុជាគឺជាប្រទេសមហាពុករលួយ ហើយបញ្ហាពុករលួយជាបញ្ហាលេខមួយ[៩]។"*

**ផ្ទុយពីកម្មវិធីនយោបាយ និងសំដីរបស់អ្នកដឹកនាំខាងលើ រាជរដ្ឋាភិបាលសម្រេចបង្កើនចំនួនមន្ត្រីនយោបាយ និងមន្ត្រីថ្នាក់ខេត្ត/ក្រុង ស្រុក/ខ័ណ្ឌ ដែលបង្កើនកម្រាស់ការិយាធិបតេយ្យ។** លោក គល់ បញ្ញា នាយកប្រតិបត្តិអង្គការ**ខុមហ្វ្រែល** បានសំដែងការព្រួយបារម្ភថា: *"ការផ្តល់តំណែងឱ្យអ្នកដែលជាបក្សពួក ដែលមិនមានលក្ខណៈសម្បត្តិគ្រប់គ្រាន់*

[៨] នៅក្នុងកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា សំរាប់នីតិកាលទី ៣ នៃរដ្ឋសភា ចំនុចទី ១៤ ទំព័រទី ១០។

[៩] វិទ្យុអាស៊ីសេរី ផ្សាយយប់ ថ្ងៃពុធ ទី ១៨ ខែសីហា ឆ្នាំ២០០៤។

*នឹងនាំឱ្យមានរដ្ឋបាលគ្មានប្រសិទ្ធភាព។"* រាជរដ្ឋាភិបាល និងតំណាងក្រុមហ៊ុនឯកជននានា (ក្នុង "វេទិការាជរដ្ឋាភិបាល និងវិស័យឯកជន) ក៏ទំនងជាទទួលស្គាល់ផងដែរថា បញ្ហាការិយាធិបតេយ្យនឹងមិនលើកទឹកចិត្តវិស័យឯកជនទេ។

ទោះបីបញ្ហាពុករលួយ និងការិយាធិបតេយ្យត្រូវបានលើកឡើងរាល់លើកក៏ដោយ ក៏បញ្ហាទាំងនេះនៅតែចោទឡើងដដែលដោយគ្មានដំណោះស្រាយ។ រាជរដ្ឋាភិបាលត្រូវបង្ហាញសមត្ថភាព ដើម្បីធ្វើឱ្យមានប្រសិទ្ធភាពជាក់ស្តែងក្នុងកិច្ចការកែទម្រង់ទាំងនេះ ព្រោះរាជរដ្ឋាភិបាលមានបទពិសោធន៍ការងាររយៈពេលជាង ១០ ឆ្នាំមកហើយ។ មានការបង្កើនប្រាក់បៀវត្សរ៍បច្ចុប្បន្នពី១០ ទៅ ១៥%សម្រាប់មន្ត្រីរាជការ ទោះបីយ៉ាងណាក៏ដោយ ក៏ការបង្កើនតិចតួចនេះជារួមគ្មានវិធានការ ឬវិធីវិធីជាក់ស្តែង ពោលគឺ មិនគ្រប់គ្រាន់ដើម្បីឱ្យមានការបន្ថយអំពើពុករលួយនិងបង្កើនប្រសិទ្ធភាព ផ្តល់សេវាទៅអ្នកប្រើប្រាស់សេវានោះទេ។

មួយវិញទៀត គេក៏នៅមានមន្ទិលផងដែរចំពោះវិធានការថ្មីៗរបស់ប្រមុខរាជរដ្ឋាភិបាល ដែលក្នុងនោះបានផ្ទេរអំណាចបែបវិសហមជ្ឈការដ៏ធំមួយឱ្យដល់ខេត្ត/ក្រុង ក្នុងការប្រមូលចំណូលពន្ធគយចូលក្នុងគណនីខេត្ត/ក្រុងរៀងៗខ្លួនតាមដែនដី។ ដូចគ្នាដែរចំពោះការផ្តល់អំណាចសម្រេចដល់ខេត្ត/ក្រុងលើកិច្ចព្រមព្រៀងវិនិយោគដែលមានតម្លៃមិនលើសពី២លានដុល្លារអាមេរិក។ តើប្រការនេះអាចនឹងនាំដល់ការកើនឡើងនូវចំនួនកុងត្រូល(ជជុះ?)ឡើងវិញដែរឬទេ? ហើយតើវិធានការណ៍បែបណានឹងត្រូវអនុវត្តសម្រាប់ធ្វើការត្រួតពិនិត្យមើលតម្លាភាព និងគណនេយ្យភាពរបស់មូលដ្ឋានខេត្ត/ក្រុងនីមួយៗ នៅពេលដែលប្រព័ន្ធត្រួតពិនិត្យ និងតុល្យភាពអំណាច (Check and balance) មិនមានការពង្រឹងនៅថ្នាក់មូលដ្ឋានខេត្ត/ក្រុងទាំងនោះ? ក្នុងករណីមានការអនុវត្តន៍យុទ្ធសាស្ត្រខាងលើនេះមានប្រសិទ្ធភាព។

ចំពោះវិមជ្ឈការហិរញ្ញវត្ថុឃុំ/សង្កាត់វិញក៏មិនទាន់ត្រូវអនុវត្តបាននៅឡើយបើយើងពិនិត្យមើលទិដ្ឋភាពសំខាន់ៗដូចជា មូលនិធិថវិកាជាតិ (វិភាជន៍) ជួយឃុំ/សង្កាត់ ច្បាប់ស្តីពីប្រភពចំណូលរបស់ឃុំ/សង្កាត់ជាដើម។

កម្មវិធីនយោបាយចំណុចទី ១៥ ក៏បានសន្យាថា រៀបចំផ្តល់មូលនិធិថវិកាឃុំ/សង្កាត់ឱ្យបាន "**សមស្រប**"។ ប៉ុន្តែពាក្យ "សមស្រប"នេះពុំត្រូវបានអនុវត្តនោះទេ ដើម្បីឱ្យមានការប្រែប្រួលមូលនិធិថវិកាឃុំ/សង្កាត់។ *មូលនិធិថវិកាឃុំ/សង្កាត់ឆ្នាំ២០០៥ នឹងទទួលបាននូវការឧបត្ថម្ភពីថវិការដ្ឋប្រមាណ៥៨ពាន់លានរៀល*[១៤,៥លានដុល្លារអាមេរិក][១០] គិតជាភាគរយស្មើនឹង១,៨២% នៃថវិកាជាតិសរុបសំរាប់ឆ្នាំ២០០៥នេះ។ តាមបរិមាណនេះឃើញថា មានកំណើនតិចតួច ឬស្ទើរតែមិនគ្រប់គ្រាន់សំរាប់ការងាររដ្ឋបាលឃុំសង្កាត់ផង ដោយមិនទាន់គិតអំពីតម្រូវការការអភិវឌ្ឍនានានៅ ឃុំ/សង្កាត់។ ជាមធ្យមឃុំ/សង្កាត់និមួយៗទទួលបានត្រឹមតែ ៨.៩៤៥ ដុល្លារអាមេរិកសំរាប់ឆ្នាំ២០០៥នេះប៉ុណ្ណោះ បើទោះបីមានការកើនឡើងចំនួន ១៦% នូវប្រាក់វិភាជន៍ប្រចាំឆ្នាំរបស់ថវិកាជាតិឱ្យដល់ឃុំ/សង្កាត់។ ប្រាក់វិភាជន៍ឆ្នាំ ២០០៥ នេះ ក៏មានប្រមាណជា ២,៥២% នៃចំណូលចរន្តថវិការដ្ឋផងដែរ ហើយចំនួនភាគរយតំណាងនេះនឹងបន្តកើនឡើងដល់ ២,៥៤% និង ២,៥៦% នៅឆ្នាំ២០០៦ និង ២០០៧ ជាបន្តបន្ទាប់តាមការសន្យាកន្លងមករបស់រាជរដ្ឋាភិបាល។ ជំនាញការធនាគារពិភពលោកបានលើកឡើងថា យ៉ាងហោចណាស់វិភាជន៍ថវិកាជាតិនេះគួរត្រូវបែងចែកដល់ឃុំ/សង្កាត់ជាមធ្យមយ៉ាងតិចចំនួន

---

[១០] *សេចក្តីថ្លែងហេតុនៃសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៥ ទំព័រទី ១៦។*

២០.០០០ដុល្លារអាមេរិក[១១] ។ បើសិនយើងពិនិត្យមើលទៅឃើញថា រាជរដ្ឋាភិបាលបានកំពុងបែងចែក**ថវិកាមិនចំទិសដៅ**សំរាប់ផលប្រយោជន៍ផ្ទាល់ដល់ការងារវិមជ្ឈការ ដោយ**ថវិកាជាច្រើនលើសលប់ ត្រូវបានដាក់ចូលខ្ទង់ថវិកា** នៃការងារ**ក្រសួងជាច្រើនសំរាប់ការងារប្រហាក់ប្រហែលគ្នា និងស្ថាប័នថ្នាក់ជាតិមិនមានប្រសិទ្ធភាពការងារជាដើម ។**

កន្លងមក តាមការសង្កេតរបស់អ្នកសង្កេតការរបស់**ខុមហ្វ្រែល**នៅតាមមូលដ្ឋាន (local watchdog) បានរកឃើញស្របជាមួយរបាយការណ៍នានាដែលបង្ហាញថា នៅមានការលំបាកចម្បងៗដែលជាបញ្ហាជាទូទៅ ចំពោះវិមជ្ឈការហិរញ្ញវត្ថុដូចជា ភាពយឺតយ៉ាវក្នុងការផ្តល់មូលនិធិរបស់រាជរដ្ឋាភិបាលទៅដល់ឃុំ/សង្កាត់ ដែលជាមធ្យមមានរយៈពេល ៤ខែ ។ *"របាយការណ៍ស្តីពីការអនុវត្តន៍នយោបាយវិមជ្ឈការឆ្នាំ២០០៣ និងទិសដៅការកិច្ចឆ្នាំ២០០៤"* របស់គណៈកម្មាធិការជាតិគាំទ្រឃុំ/សង្កាត់ឱ្យដឹងថា ជាក់ស្តែងរហូតមកដល់ឆ្នាំ២០០៤ សាច់ប្រាក់ដែលមិនទាន់បានធ្វើការផ្ទេរសំរាប់មូលនិធិឃុំ/សង្កាត់ឆ្នាំ២០០៣ មានចំនួន ៩.២៨១ លានរៀល ស្មើនឹង ២១,៦% នៃវិភាជន៍ថវិកាជាតិសរុបសំរាប់ឃុំ/សង្កាត់ប្រចាំឆ្នាំ ។ នៅក្នុងបរិមាណមូលនិធិត្រូវផ្ទេរដែលយឺតយ៉ាវខាងលើនេះ ៧០% គឺជាមូលនិធិសំរាប់ផ្នែកអភិវឌ្ឍន៍មូលដ្ឋាន ។ ដូចគ្នាដែរ វិភាជន៍នៅឆ្នាំ២០០៤ ក៏មានភាពយឺតយ៉ាវផងដែរគិតត្រឹមខែធ្នូ ។ ដូច្នេះភាពយឺតយ៉ាវនេះបានបង្ហាញយ៉ាងច្បាស់នូវទំនាក់ទំនងនាំទៅដល់ភាពយឺតយ៉ាវដល់ការអភិវឌ្ឍមូលដ្ឋានជាទូទៅ ។ ដើម្បីដោះស្រាយបញ្ហានេះមានការណែនាំឱ្យមានការប្រើប្រាស់គណនីរបស់ធនាគារពាណិជ្ជកម្មសំរាប់ឃុំ/សង្កាត់ ជាជាងការបន្តប្រើប្រាស់គណនីរតនាគារខេត្ត/ក្រុងដែលមានបញ្ហា និងអសកម្មក្នុងការផ្ទេរមូលនិធិឃុំ/សង្កាត់នេះ ។

## ៦. នយោបាយការពារជាតិ និងសន្តិសុខ

រាជរដ្ឋាភិបាលត្រូវធានាសន្តិសុខ សុវត្ថិភាព និងភាពសុខដុមចំពោះជីវភាពប្រចាំថ្ងៃរបស់សង្គមផងខ្លួន ។ ប៉ុន្តែជំនួសឱ្យការចាប់ផ្តើមបំពេញនិងធ្វើឱ្យប្រសើរឡើងនូវសេចក្តីត្រូវការចាំបាច់នេះ នៅក្នុងរយៈពេល៦ខែ ក្រោយការបង្កើតរាជរដ្ឋាភិបាលអាណត្តិទី៣ គេសង្កេតឃើញស្ថានភាពជារួមថា រាជរដ្ឋាភិបាលកំពុងបន្តកិច្ចការចាស់ខ្លះ ហើយកំពុងជួបប្រទះបញ្ហាថ្មីមួយចំនួន និងមិនទាន់មានការចាប់ផ្តើមជម្រុញការអនុវត្តន៍កិច្ចសន្យានៅឡើយនៅក្នុងវិស័យ**នយោបាយការពារជាតិ និងសន្តិសុខ** ដែលបានដាក់ចេញយ៉ាងទូលំទូលាយចំនួន៧ចំណុច (ចំណុចទី១៦ ដល់ទី២២) នៅក្នុងកម្មវិធីនយោបាយ៧៣ចំណុចរបស់ខ្លួន ។

របាយការណ៍នេះនឹងពិនិត្យមួយចំណុចម្តងៗ ដូចជាចំណុចទី១៦ ដែលនិយាយទៅដល់ *"ការជម្រុញកិច្ចការកែទម្រង់កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ ក្នុងនោះមានការត្រួតពិនិត្យចំនួនទ័ពឱ្យបានពិតប្រាកដដោយសំដៅពង្រឹងគុណភាព ធានានូវភាពស្មោះត្រង់ជានិច្ចចំពោះជាតិ...ធានាឱ្យមាននូវវិន័យ និងសីលធម៌ស្អាតស្អំ..."* នៅមិនទាន់ឃើញមានសកម្មភាពធំដុំណាអំពីបញ្ហានេះនៅឡើយ ។ ជាក់ស្តែង សម្តេច នាយករដ្ឋមន្ត្រី បានដាក់**បញ្ជាយ៉ាងតឹងរ៉ឹង**តាំងពីអាណត្តិមុនទៅលើការលុបបំបាត់**កុងត្រូលជជុះ** ប៉ុន្តែរហូតមកដល់អាណត្តិនេះ និងនៅពេលនេះ សម្តេចនាយករដ្ឋមន្ត្រីបានត្រឹមតែ**អង្វរអំពាវនាវ**សុំកុំឱ្យមានកុងត្រូលជជុះទៅវិញ ដែលស្ថានភាពនេះសរបញ្ជាក់អំពី**វិន័យ និងសីលធម៌ចុះខ្សោយរបស់កងកម្លាំងមាន**

[១១] *"កម្ពុជាលើផ្លូវបំបែក"* របាយការណ៍ធនាគារពិភពលោក ថ្ងៃទី ១៥ តុលា ២០០៤ ទំព័រទី ១០៦ ។

**សមត្ថកិច្ច**ពាក់ព័ន្ធ។ ចំណែកចំណុចទី១៧ ចែងថា: *"រាជរដ្ឋាភិបាលនឹងបន្តកសាងនិងពង្រឹងកងយោធពលខេមរភូមិន្ទ...ដែលមានបរិមាណសមល្មម..."* តែមិនមានការបញ្ជាក់អំពីចំនួនសមល្មមនោះនៅក្នុងកម្រិតណាមួយនិងតាមវិធីសាស្ត្ររៀបចំយ៉ាងណាឡើយ។ ផ្ទុយទៅវិញ ដោយគ្មានការចែងឱ្យច្បាស់លាស់នូវរឿងនេះ រាជរដ្ឋាភិបាលបានលើកសំណើក្រៅកម្មវិធីនយោបាយថានឹងរៀបចំសេចក្តីព្រាងច្បាប់**ច្បាប់កាតព្វកិច្ចយោធា**។ តើកាតព្វកិច្ចយោធានេះអាចនិយាយបានថា ជួយជម្រុញឱ្យមាន**បរិមាណសមល្មម**ដែរឬទេ? ហើយចុះចំពោះគុណភាពវិញ?

ចំណុចទី១៨ បានលើកឡើងថា *"រាជរដ្ឋាភិបាលនឹងបង្កើនការយកចិត្តទុកដាក់បណ្តុះបណ្តាលវិជ្ជាជីវៈ និងជួយបង្កលក្ខណៈដោះស្រាយជីវភាពចំពោះយោធិនរំសាយ..."* ប៉ុន្តែចំពោះរឿងនេះ ធនាគារពិភពលោកបានរកឃើញថា មូលនិធិចំនួន ២,៨ លានដុល្លារអាមេរិកត្រូវបានប្រើប្រាស់ខុស និងអាចជាប់ពាក់ព័ន្ធនឹងអំពើពុករលួយចំពោះការអនុវត្តន៍កម្មវិធីដោះស្រាយជីវភាពដល់កងទ័ពដែលត្រូវកាត់រំសាយ ហើយជាលទ្ធផល រាជរដ្ឋាភិបាលបាន**ធ្វើការទូទាត់សងជាបន្ទាន់ និងប្រកាសឈប់សហការ**ជាមួយធនាគារនេះក្នុងកម្មវិធីកាត់រំសាយទ័ព។ តើរាជរដ្ឋាភិបាល អាចដោះស្រាយរកដៃគូសហការគាំទ្រថ្មីទៀតដើម្បីបន្តគម្រោងនេះទាន់ពេលវេលាឬទេ?

កម្មវិធីនយោបាយចំណុចទី១៩ បានចែងដែរថា *"រាជរដ្ឋាភិបាលនឹងបន្តកសាង និងពង្រឹងកងកម្លាំងនគរបាលជាតិឱ្យ...គោរពប្រតិបត្តិច្បាប់ម៉ឺងម៉ាត់ គោរពសិទ្ធិមនុស្ស បំរើប្រជាពលរដ្ឋដោយស្មោះត្រង់ មានសមត្ថភាពសំរេចបានល្អនូវភារកិច្ចគ្រប់គ្រង និងថែរក្សាសន្តិសុខសណ្តាប់ធ្នាប់ សាធារណៈជាអាទិ៍ ការការពារអាយុជីវិត និងទ្រព្យសម្បត្តិរបស់ប្រជាពលរដ្ឋ ការការពារប្រជាពលរដ្ឋក្នុងការបញ្ចេញមតិតាមរយៈការធ្វើបាតុកម្មកូដកម្មស្របច្បាប់ព្រមទាំងរក្សាបាននូវភាពសុខដុមរមនានៅក្នុងសង្គម។"* ប៉ុន្តែជាញឹកញាប់ បណ្តាញសារព័ត៌មានបានរាយការណ៍អំពីករណីរំលោភដីធ្លី ឬការពារ (កាង) បទល្មើសខុសច្បាប់ពីសំណាក់កងកម្លាំងប្រដាប់អាវុធទៅវិញ។ លោក **ធន សារាយ** ប្រធានសមាគមអាដហុកក៏បានមានប្រសាសន៍ (នៅថ្ងៃទី២៦ មករា ២០០៥) យោងទៅដល់បញ្ហាសន្តិសុខសង្គម និងការកើតឡើងនូវបទល្មើសនានាផងដែរថា: *"មូលហេតុចម្បងៗដែលនាំទៅដល់ការកកើតឡើងនូវបទល្មើសនៅពាសពេញប្រទេសមានដូចជា ការអនុញ្ញាតឱ្យមានបនល្បែងស៊ីសងកាស៊ីណូ ភាពគ្មានការងារធ្វើ ការកើនឡើងនូវចោរាចរនិងការប្រើប្រាស់គ្រឿងញៀន ការបាត់បង់ជំនឿទុកចិត្តលើប្រព័ន្ធតុលាការ និងការពង្រឹងសមត្ថភាពកងកម្លាំងមានសមត្ថកិច្ចមិនបានត្រឹមត្រូវ។ ហើយមូលហេតុទាំងអម្បាលម៉ាននេះ មិនត្រូវបានយកចិត្តទុកដាក់ទប់ស្កាត់ ឬបង្ក្រាបឱ្យមានប្រសិទ្ធភាពឡើយ"*។

ដោយឡែកចំណុចទី២០ដែលនិយាយអំពី *"...ការចូលរួមជាមួយនឹងសហគមន៍អន្តរជាតិ ក្នុងការបង្កើនកិច្ចសហប្រតិបត្តិការដើម្បីទប់ស្កាត់ និងប្រឆាំងរាល់សកម្មភាពភេរវកម្មតាមគ្រប់រូបភាព..."* ត្រូវបានកត់សម្គាល់ឃើញថាមានការរីកចម្រើនស្របតាមចរន្តសកម្មភាពអន្តរជាតិ ដោយកន្លងមករាជរដ្ឋាភិបាលបានសម្រេចចិត្តជាឯកតោភាគីបំផ្លាញគ្រាប់មីស៊ីលប្រឆាំងយន្តហោះជាច្រើនគ្រាប់ ព្យាយាមសហការជាមួយប្រទេសពាក់ព័ន្ធតាមចាប់ខ្លួនភេរវករអន្តរជាតិ និងផ្តួចផ្តើមធ្វើសេចក្តីព្រាងច្បាប់ប្រឆាំងភេរវកម្មជាដើម។ ទោះបីយ៉ាងណា លោក Heraldo Munoz ប្រធានគណៈកម្មាធិការក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ ស្តីពីការដាក់ទណ្ឌកម្មប្រឆាំងក្រុមភេរវកម្ម ធ្លាប់បាននិយាយនៅថ្ងៃទី ២២ តុលា ២០០៤ ថា: *"ប្រទេសកម្ពុជាត្រូវការកិច្ចសហប្រតិបត្តិការអន្តរជាតិជាបន្ទាន់ដើម្បីមានសមត្ថភាព ប្រឆាំងនឹងភេរវកម្ម។*

*ប្រទេសកម្ពុជាដែលមានរចនាសម្ព័ន្ធប្រឆាំងភេរវកម្មខ្សោយអាចក្លាយជាជម្រកដល់ប្រតិបត្តិការពួកភេរវករJemaahIslamiyah និងក្រុមពាក់ព័ន្ធជាមួយបណ្តាញAl-Qaida ។"* នៅក្នុងចំណុចទី២០ដដែលនេះអ្វីដែល *"រាជរដ្ឋាភិបាលសំដៅបង្កើនប្រសិទ្ធភាពការងារទប់ស្កាត់ និងបង្ក្រាបបទល្មើសគ្រប់ប្រភេទ ពិសេសការជួញដូរ និងប្រើប្រាស់គ្រឿងញៀន ការជួញដូរស្ត្រីនិងកុមារ អំពើចាប់ជំរិតប្លន់ប្រដាប់អាវុធ ការរំលោភផ្លូវភេទ និងសកម្មភាពល្មើសច្បាប់ផ្សេងៗទៀត ដែលបង្កឱ្យមានការភ័យខ្លាចក្នុងសង្គមនិងធ្វើឱ្យសីលធម៌ធ្លាក់ចុះ"* បែរជាបង្ហាញលទ្ធផលមិនច្បាស់លាស់នៅដើមឆ្នាំនេះបន្តពីឆ្នាំចាស់ ។នៅចុងឆ្នាំ២០០៤ លោក Graham Shaw មន្ត្រីកម្មវិធីនៃការិយាល័យអង្គការសហប្រជាជាតិស្តីពីគ្រឿងញៀន និងបទឧក្រិដ្ឋ (UNODC) បាននិយាយថា: ***"ការជួញដូរគ្រឿងញៀននៅកម្ពុជា មិនអាចគ្រប់គ្រងបាន** (out of control)[១២] "* ។ ហើយជាក់ស្តែងថ្មីៗនេះទៀតសោត មានរឿងអាស្រូវក្នុងការដោះស្រាយបញ្ហាចម្រូងចម្រាស់ករណីនារីរងគ្រោះរវាងសណ្ឋាគារឆាយហ៊ួរ២និង អង្គការអាហ្វេស៊ីប (Afesip) ដែលបង្កើតជាអន្តរាគមន៍ និងការរិះគន់ជាច្រើនពីសំណាក់ស្ថានទូតអន្តរជាតិមួយចំនួន ។ លើសពីនេះទៀត ការចាប់រំលោភសេពសន្ថវៈលើស្ត្រី និងកុមារត្រូវបានរាយការណ៍ថា: *"កាន់តែមានសភាពធ្ងន់ធ្ងរជាងមុន ពោលគឺមានការកើនឡើងករណីសម្លាប់ជនរងគ្រោះក្រោយពេលចាប់រំលោភរួច[១៣] "* ។

ការបង្កើតក្រសួងអន្តោប្រវេសន៍ និងសញ្ជាតិតាមការប្តេជ្ញារបស់រាជរដ្ឋាភិបាល (យោងតាមចំណុចទី២១នៃកម្មវិធីនយោបាយ៧៣ចំណុច) នៅមិនទាន់មានតំរុយចាប់ផ្តើម ឬក៏ជជែកពិភាក្សានៅឡើយ ដោយសារការថែងអំពី *"ការពិនិត្យលទ្ធភាពបង្កើតនៅក្នុងរយៈពេលសមស្រប"* មិនមានភាពច្បាស់លាស់ ។

និយាយពីកំណែទម្រង់កងកម្លាំងប្រដាប់អាវុធវិញគឺ សំដៅលើការរៀបចំ និងការកាត់រំសាយកងទ័ព ។ បន្ថែមពីលើការងារ កែទម្រង់មិនទាន់ដោះស្រាយថ្មីៗនេះ កាលពីថ្ងៃ៣ កញ្ញា ២០០៤ រាជរដ្ឋាភិបាលបានអនុម័តលើសេចក្តីព្រាងច្បាប់កាតព្វកិច្ចយោធា ។ មានន័យថា ចំនួនកងទ័ពនឹងកើនឡើង ហើយដែលត្រូវបានអះអាងថា **ជាជំហានមួយនៃកំណែទម្រង់កងកំលាំងប្រដាប់អាវុធរបស់រាជរដ្ឋាភិបាលអាណត្តិទី៣ទៅវិញ** បន្ទាប់ពីការផ្អាកការអនុវត្តន៍គម្រោងកាត់រំសាយទ័ពតាំងពីរាជរដ្ឋាភិបាលអាណត្តិទី២មក ។

ហើយជាដំណើរផ្ទុយគ្នានេះផងដែរ ឯកឧត្តម **ទៀ បាញ់** សហរដ្ឋមន្ត្រីក្រសួងការពារជាតិបានយល់ព្រមបង្កើតតំណែងមេបញ្ជាការរងថ្មីក្នុងគ្រប់អង្គភាពកងយោធពលខេមរភូមិន្ទ សម្រាប់នាយទាហានមកពីគណបក្សហ៊្វុនស៊ិនប៉ិចជាង ១០០កន្លែង[១៤] ដែលជាលទ្ធផលមួយនៃការសម្របសម្រួលនយោបាយរវាងគណបក្សប្រជាជនកម្ពុជា និងហ៊្វុនស៊ិនប៉ិច ។ ការផ្តល់តំណែងដូច្នេះ ត្រូវបានមើលឃើញថា**គ្មានតម្លាភាព** និងជាការ**បន្ថែមបន្ទុកចំណាយរដ្ឋ** ហើយឈរលើគោលការណ៍ **ភាពលម្អៀងនយោបាយ** ចំពោះនាយទាហានឬមេបញ្ជាការ ។ **ហេតុអ្វីពួកគេត្រូវបានជ្រើសរើសចេញពីគណបក្សនយោបាយទៅវិញ?** ការបង្កើតតំណែងមេបញ្ជាការរងថ្មីនេះផ្ទុយនឹងប្រសាសន៍ថ្នាក់ដឹកនាំរាជរដ្ឋាភិបាលដូចជាប្រសាសន៍របស់សម្តេច **ហ៊ុន សែន** ក៏ដូចជាឯកឧត្តម **ញឹក ប៊ុនឆៃ** ថា: *"ព្រះរាជាណាចក្រកម្ពុជាបច្ចុប្បន្ន មានមេបញ្ជាការច្រើន ប៉ុន្តែកូនទាហាន*

---

[១២] Phnom Penh Post, ***"Drug Trafficking "out of control" says UN"***, December 17-30, 2004.

[១៣] សមាគមអាដហុក "**ស្ថានភាពសិទ្ធិមនុស្ស ២០០៤**" ខែ មករា ឆ្នាំ ២០០៥ ។

[១៤] ឌឹ ឃែមបូឌា ដេលី ថ្ងៃអង្គារ ទី២៤ ខែសីហា ឆ្នាំ ២០០៤ "**យោធពលខេមរភូមិន្ទរៀបកន្លែងសំរាប់នាយទាហានគណបក្សហ៊្វុន ស៊ិនប៉ិច**" ។

*តិចតួច។"* ម្យ៉ាងវិញទៀត ឯកឧត្តម **កែ គឹមយ៉ាន** ដែលបានរំពឹងលើកាតព្វកិច្ចយោធាក៏បានសារភាពដែរថាៈ *"កងទ័ពកម្ពុជា [បច្ចុប្បន្ន] ត្រូវបានធ្វើឱ្យខូចដោយនយោបាយ ហើយទាហានចាស់ៗប្រកាន់បក្សពួក និងពាក់ព័ន្ធនឹងនយោបាយ។"*

## ៧. កំណែទម្រង់ គ្រប់គ្រងដីធ្លី

កាលពីថ្ងៃទី១៨ ខែតុលា ២០០៤កន្លងទៅនេះនៅឯក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា សម្តេចនាយករដ្ឋមន្ត្រី **ហ៊ុន សែន** បានលើកឡើងវិញស្តីពី **បញ្ហាកំណែទម្រង់ដីធ្លី** នៅកម្ពុជាដោយសម្តេចបានប្រកាសនូវ**វិធានការណ៍តឹងរ៉ឹង** ដើម្បីបំបាត់ការកាន់កាប់ដីខុសច្បាប់ សកម្មភាពរឹបអូសនិងការរំលោភយកដីប្រជារាស្ត្រពីសំណាក់អ្នកមានអំណាច។ ខណៈនោះក៏មានការ**ទទួលស្គាល់ផងដែរនូវកំហុសក្នុងជីវិតនយោបាយរបស់លោក**ដែលមានការកែទម្រង់ដីធ្លី និងកំណែទម្រង់ឡូតិ៍នៃសាទយឺត ហើយនិងមានការសន្យាដ៏ឧឡារឹកដែលទំនងជាមធ្យ៉តមួយពីប្រមុខរាជរដ្ឋាភិបាល ដោយបាននិយាយថាៈ *"...ឈ្មោះ ក កាន់កាប់ដីខុសច្បាប់១០០០ហិកតា....បើខ្ញុំមិនធ្វើទេខ្ញុំចាកចេញពីតំណែង..."*។ តាមពិត ទាំងនេះជាការអនុវត្តន៍ទៅតាមអ្វីដែលស្របនឹង**កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជាសំរាប់នីតិកាលទី៣នៃរដ្ឋសភា** ក៏ដូចជា នៅក្នុង**យុទ្ធសាស្ត្រចតុកោណៈ** *"...រាជរដ្ឋាភិបាលប្រមូលផ្តុំជាសំខាន់លើវិធានការពង្រឹងប្រព័ន្ធគ្រប់គ្រងបែងចែក និងប្រើប្រាស់ដីធ្លីប្រកបដោយសមធម៌ និងដោយធានាបាននូវប្រសិទ្ធភាពសេដ្ឋកិច្ច...ការលុបបំបាត់ភាពអនាធិបតេយ្យក្នុងការកាន់កាប់ដីដោយខុសច្បាប់ ការដាក់ចេញវិធានការសមស្រប ដើម្បីទប់ស្កាត់ការប្រមូលដីទុកដោយមិនប្រើប្រាស់មិនធ្វើផលិតកម្ម ឬអាជីវកម្ម។ល។"*

អ្នកសង្កេតការណ៍នានាទទួលស្គាល់ថា បញ្ហាដីធ្លីជាបញ្ហាស្មុគស្មាញនៅកម្ពុជា ហើយក៏ជាបញ្ហាស្លាប់រស់មួយរបស់ប្រទេសនេះផងដែរ។ តាមការឱ្យដឹងពីវេទិកាសាធារណៈជាច្រើនរបស់អង្គការ**ខុមហ្វ្រែល** ក៏ដូចជាសកម្មភាពបាតុកម្មជាក់ស្តែងរបស់ប្រជាពលរដ្ឋ ក្នុងការទាមទាររកយុត្តិធម៌នៅរាជធានីភ្នំពេញ ជារឿយៗលើបញ្ហាដីធ្លីពីមូលដ្ឋាន **គេសង្កេតឃើញថា បញ្ហាការរឹបអូសរំលោភយកដីធ្លីដោយអ្នកមានអំណាចជាបញ្ហាធ្ងន់ធ្ងរ** ដែលតម្រូវជាចាំបាច់ឱ្យមានការដោះ-ស្រាយទន្ទឹមនឹងការកែទម្រង់ទាន់ពេលវេលាមួយ។ ម្យ៉ាងវាជាជម្រើសល្អមួយដែលគាំទ្រដល់គោលនយោបាយកាត់បន្ថយភាពក្រីក្ររបស់រាជរដ្ឋាភិបាល ដោយហេតុថាប្រជាជនកម្ពុជា ៨០% ជាកសិកររំពឹងលើទឹកដី ដើម្បីប្រកបរបរស្រែចំការចិញ្ចឹមជីវិត។ ទាំងអស់នេះសុទ្ធតែជាបញ្ហា ដែលមាននៅប្រទេសកម្ពុជាពាក់ព័ន្ធនឹងបញ្ហាកំណែទម្រង់ដីធ្លី ដូចដែល**ឯកសារតាមវិស័យ និងបញ្ហានានារបស់អង្គការ-សមាគមមិនមែនរដ្ឋាភិបាល**ក្នុងឆ្នាំ២០០៤ ក៏ដូចឆ្នាំមុនបានរកឃើញបញ្ហាគន្លឹះបី ពាក់ព័ន្ធនឹងកំណែទម្រង់នេះគឺៈ (១) <u>រដ្ឋបាលដីធ្លី</u> *ដែលដំណើរការនៃការចុះបញ្ជីពុំបានទូលំទូលាយ និងមិនបង្កលក្ខណៈងាយស្រួលដល់ប្រជាជនពេលនោះនឹងរឹតតែធ្វើឱ្យកម្រិតជីវភាពរបស់ប្រជាជនជួបការលំបាកថែមទៀត* (២) <u>វិវាទដីធ្លី</u> *ដែលតែងតែកើតឡើងរវាងប្រជាជនច្រើនគ្រួសារជាមួយអ្នកមានទឹកប្រាក់ ឬអ្នកមានអំណាចទៅលើដីភោគៈ* និង (៣) <u>ការបែងចែកដីធ្លី</u> *ដែលពុំទាន់មានកិច្ចការជាក់លាក់ណាមួយនៃគម្រោងការបែងចែកដីធ្លីបានអនុវត្តជាក់ស្តែងនៅឡើយ ប៉ុន្តែតម្រូវការដីធ្លីចេះតែកើនឡើងជារៀងរាល់ឆ្នាំ ឯការផ្តត់ផ្គង់ដីធ្លីដែលត្រូវបានលើកយកមកពិភាក្សាមាននៅតែលើក្រដាស ប៉ុន្តែចំណាត់ការជាក់ស្តែងពុំទាន់បានកើតឡើង។*

## ៨. ចំណុចរសើបស្តីពីអាជីវកម្មលើផ្លូវជាតិលេខ៤

ដោយឡែកថ្មីៗនេះ ចំណុចរសើបមួយ ក្នុងចំណោមចំណុចទាំង ៧៣ នៃកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល (ចំណុច៤៨ *"រាជរដ្ឋាភិបាលត្រួតពិនិត្យ និងវាយតម្លៃលើកិច្ចសន្យាពាក់ព័ន្ធនឹងអាជីវកម្មលើផ្លូវជាតិលេខ ៤ ក្នុងនោះរួមមានការបង់ថ្លៃប្រើប្រាស់ផ្លូវ សំរាប់យានយន្តគ្រប់ប្រភេទដែលធ្វើចរាចរលើដងផ្លូវជាតិនេះ"*) មិនទាន់បានអនុវត្តពេញលេញដោយរាជរដ្ឋាភិបាល។ ការមិនអនុវត្តនេះបានកំពុងបង្កើតបរិយាកាសមិនគួរជាទីពេញចិត្តពីសំណាក់ប្រជាពលរដ្ឋតាមរយៈការបង់ថ្លៃក្នុងអត្រាខ្ពស់មួយធៀបនឹងប្រាក់ចំណូលជាមធ្យមរបស់ប្រជាពលរដ្ឋលើការប្រើប្រាស់ផ្លូវជាតិលេខ៤។ គួររលឹកផងដែរថា ដើមឡើយការស្ថាបនាផ្លូវជាតិលេខ៤ គឺបានមកពីជំនួយឥតសំណងរបស់រដ្ឋាភិបាលសហរដ្ឋអាមេរិក។ ប៉ុន្តែរាជរដ្ឋាភិបាលកម្ពុជាបានធ្វើកិច្ចព្រមព្រៀងសម្បទានជាមួយនឹងក្រុមហ៊ុនអេហ្សិត (AZ Investment Co., Ltd)[១៥] ដើម្បីវិនិយោគជួសជុល និងថែទាំ ហើយយកកំរៃពីប្រជាពលរដ្ឋ(យានយន្តគ្រប់ប្រភេទ) ក្នុងការប្រើប្រាស់ផ្លូវដោយអះអាងថាជាការយកថ្លៃជួសជុលថែរក្សា ហើយបានចាប់អនុវត្តពេញលេញកាលពីថ្ងៃទី ៣ មករា ២០០៥។ ដោយសារតែកំរៃត្រូវបង់ខ្ពស់នាំឱ្យមានកូដកម្មតវ៉ាភាគច្រើនពីសំណាក់អ្នករត់តាក់ស៊ី និងអ្នកប្រើប្រាស់ផ្លូវជាទូទៅ ហើយមានរហូតដល់ការប្រើអំពើហឹង្សាវាយដំ និងការចាប់ឃុំខ្លួនអ្នកតំណាងតវ៉ាចំនួន២នាក់ពីសំណាក់កំលាំងមានសមត្ថកិច្ចទៀតផង។ កិច្ចសន្យាដែលប៉ះពាល់ប្រយោជន៍ដោយផ្ទាល់របស់ប្រជាពលរដ្ឋ ទាំងសិទ្ធិក្នុងការធ្វើដំណើរ និងសេដ្ឋកិច្ចជាតិដូចនេះ គួរត្រូវសើរើ និងវាយតម្លៃជាថ្មីឡើងវិញ។ តាមប្រសាសន៍លោក **ធន សារាយ** បានថ្លែងថា: *"ជាការពិត រាជរដ្ឋាភិបាលមានលទ្ធភាពសើរើត្រួតពិនិត្យលើវិនិយោគប្រភេទនេះ និងរកដំណោះស្រាយ។ ការសើរើនេះក៏រួមពិនិត្យទៅលើកិច្ចព្រមព្រៀងសម្បទាន ដែលប៉ះពាល់ដល់សិទ្ធិធ្វើដំណើររបស់ប្រជាពលរដ្ឋ។"* ប្រជាពលរដ្ឋមានសិទ្ធិធ្វើដំណើរលើផ្លូវមួយទៀតដោយឡែកស្របផ្លូវជាតិលេខ៤ ដោយមិនចាំបាច់បង់លុយ។ ការតម្រូវឱ្យបង់លុយនេះគឺខ្ពស់ពេកបើប្រៀបធៀបជីវភាពប្រជាពលរដ្ឋបច្ចុប្បន្ន ឧទាហរណ៍ ក្នុងបរិមាណតំលៃត្រូវបង់ចំនួន ៣.០៨ ដុល្លារអាមេរិក (១២.៤០០ រៀល) ដោយរថយន្តតាក់ស៊ី (ដែលដឹកអ្នកដំណើរពេញ៧នាក់) ប្រជាពលរដ្ឋម្នាក់ៗ ជាអ្នកធ្វើដំណើរសាមញ្ញ ហើយភាគច្រើនក្រីក្រ ចូលរួមចំណែកបង់ជាមធ្យមពន្ធបន្ថែម ១.៨០០ រៀល(ដោយមិនទាន់គិតតម្លៃជាក់ស្តែងសំរាប់បង់ឱ្យរថយន្តតាក់ស៊ី) ចំពោះការប្រើប្រាស់ផ្លូវជាតិលេខ៤ទៅមកភ្នំពេញក្រុងព្រះសីហនុ។ វាជាបរិមាណមួយមិនសមស្របនឹងចំណូលជីវភាពប្រជាពលរដ្ឋ ដែលជាមធ្យមរកចំណូលមិនបាន ១ ដុល្លារអាមេរិកក្នុង១ថ្ងៃ (GDPក្នុងប្រជាជនម្នាក់រកបាន ៣០៦ ដុល្លារអាមេរិកក្នុង១ឆ្នាំ[១៦])។

ម្យ៉ាងទៀត របាយការណ៍រកឃើញថា កិច្ចព្រមព្រៀងសម្បទានធ្វើឡើងគ្មានតម្លាភាព។ ក្រុមហ៊ុនទទួលកិច្ចព្រមព្រៀងដោយគ្មានការដេញថ្លៃ។ រាជរដ្ឋាភិបាលមិនបានសិក្សាឱ្យត្រឹមត្រូវអំពីលទ្ធភាពរកចំណូលនិងចំណាយលើផ្លូវជាតិនេះ និងពិសេសផលប៉ះពាល់នៃកិច្ចសន្យានេះ។ គ្មានព័ត៌មាន និងការបកស្រាយច្បាស់លាស់ថា ហេតុអ្វីបានជាឱ្យក្រុមហ៊ុននេះយកតម្លៃតំលៃដូចនេះ។ បើទោះជាកិច្ចព្រមព្រៀងនេះមិនបានផ្តល់លទ្ធភាពឱ្យក្រុមហ៊ុនពង្រីកផ្លូវ ក្រុមហ៊ុនបានអះអាងថា

---

[១៥] ចុះថ្ងៃទី ២៨ ខែមិនា ឆ្នាំ២០០១ ស្តីពីការវិនិយោគ ជួសជុល ថែទាំផ្លូវជាតិលេខ ៤ និង លិខិតអនុញ្ញាតលេខ ១៣២៥ សជណ ចុះថ្ងៃទី ១៨ ខែវិច្ឆិកា ឆ្នាំ ២០០៤ របស់ទីស្តីការគណៈរដ្ឋមន្ត្រី។

[១៦] Economic Institute of Cambodia, *"Cambodia Economic Watch"*, Key Economic Indicators, October 2004.

ខ្លួនយកថ្លៃដូច្នេះព្រោះយកទៅពង្រីកផ្លូវ ហើយបានដេញប្រជាពលរដ្ឋរស់នៅ និងរកស៊ីតាមដងផ្លូវនោះដោយគ្មានសំណង ឬមានសំណងតិចតួចបំផុត។ បច្ចុប្បន្នប្រជាពលរដ្ឋអ្នករកស៊ីតាមផ្លូវនេះ ដែលរស់នៅចន្លោះទីតាំងយកលុយរវាងខេត្ត កណ្តាល និងក្រុងព្រះសីហនុ ទទួលផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរ ព្រោះថាសកម្មភាពរថយន្តដឹកអ្នកទៅទិញឥវ៉ាន់ ឬទៅហូប ចុកផ្សេងៗមានការថយចុះ។

ចំពោះបរិមាណចំណាយជួសជុលថែរក្សាផ្លូវជាតិលេខ៤នេះ រាជរដ្ឋាភិបាលអាចរ៉ាប់រងបានយ៉ាងងាយស្រួលក្នុង ករណីមានការគ្រប់គ្រងចំណាយថវិកាជាតិត្រឹមត្រូវ។ ឆ្នាំនេះមានកំណើនចំណាយថវិកាជាតិ ប៉ុន្តែគេមើលឃើញថាបានធ្វើ ឡើងមិនចំទិសដៅ និងគ្មានប្រសិទ្ធភាពក្នុងការបម្រុងថវិកាមួយចំនួនដូចជា ចំណាយលើប្រាក់បៀវត្សរ៍របស់សមាជិក រាជរដ្ឋាភិបាលថ្មីច្រើនហួសហេតុ (សមាជិកគណៈរដ្ឋមន្ត្រីជាង៣០០នាក់ដែលអាចចំណាយកើនឡើងលើសពីអាណត្តិមុន ចំនួន ៥៣៦.៤០០ ដុល្លារអាមេរិកក្នុង១ឆ្នាំ[១៧]) របស់រាជរដ្ឋាភិបាលអាណត្តិទី ៣ ចំពោះប្រទេសតូច ហើយមានប្រជាជន ក្រីក្រច្រើន។

យ៉ាងណាក៏ដោយ ប្រជាពលរដ្ឋពិសេសក្រុមជនរងគ្រោះពីការយកប្រាក់ប្រើប្រាស់ផ្លូវជាតិលេខ៤នេះកំពុងអំពាវនាវ និងស្វែងរកដំណោះស្រាយពីសំណាក់រាជរដ្ឋាភិបាល និងអាជ្ញាធរមានសមត្ថកិច្ច ដោយសង្ឃឹមថានឹងមានការបន្ធូរបន្ថយ តម្លៃតំលៃឱ្យបានដល់កម្រិតសមស្របមួយ។ **ហើយវាជាការអាម៉ាសរបស់រាជរដ្ឋាភិបាលដែលមិនត្រឹមតែមិនគោរពតាម កិច្ចសន្យាក្នុងកម្មវិធីនយោបាយរបស់ខ្លួន តែថែមទាំងប្រើអំពើហឹង្សា បង្ករហួសស្នាមដល់កូដករ និងបំពានសិទ្ធិរបស់ ប្រជាពលរដ្ឋ។**

## ៩. កំណើនការងារ

មានការប្រឈមមុខ និងភាពមិនប្រាកដប្រជាក្នុងការអនុវត្តន៍នយោបាយបង្កើនការងារ ដូចជាចំណុចទី៦៣ និង ៦៤ នៃកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល ដែលចែងអំពី *"ការជំរុញអនុវត្តគោលនយោបាយជាប្រព័ន្ធ និងជាខ្សែសង្វាក់ សំដៅបង្កើតការងារឱ្យបានច្រើនជូនដល់ស្រទាប់យុវវ័យដែលត្រូវដល់អាយុឈានចូលទីផ្សារពលកម្ម និងពលករកម្ពុជាទាំង អស់...ការលើកទឹកចិត្តដល់ការវិនិយោគក្នុងស្រុក និងទាក់ទាញវិនិយោគផ្ទាល់ពីបរទេស...បង្កើតបណ្តាញបណ្តុះបណ្តាល ជំនាញវិជ្ជាជីវៈជូនជនក្រីក្រ ដែលផ្សារភ្ជាប់ជាមួយនឹងមជ្ឈមណ្ឌលសំរាប់ជួយរកការងារធ្វើឱ្យយុវជន...ការរៀបចំប្រព័ន្ធស្ថិតិ ការងារ...ការគ្រប់គ្រងពលករបរទេសនៅកម្ពុជា...ការត្រួតពិនិត្យតាមដានពលករខ្មែរដែលនាំចេញទៅក្រៅប្រទេស...ការ ធានានូវសិទ្ធិនិងផលប្រយោជន៍របស់កម្មករនិយោជិត..."* រួមទាំងយុទ្ធសាស្ត្រចតុកោណបង្ហាញអំពី *អាទិភាពក្នុងការបង្កើត ការងារ*ផងដែរ។

ការប្រឈមមុខនោះកំពុងកើតមាននៅក្នុងវិស័យការងារនៃវិស័យកសិកម្ម ឧស្សាហកម្ម និងសេវាកម្ម។ ឆ្នាំ ២០០៥បានចាប់ផ្តើមជាមួយនឹងការកត់សម្គាល់អំពីការបញ្ចប់កូតាសំលៀកបំពាក់កម្ពុជានៅលើទីផ្សារអាមេរិក ដែលធ្វើឱ្យ មានមន្ទិលជាទូទៅ នូវលទ្ធភាពបាត់បង់ទីផ្សារការងារចំនួនប្រមាណជាង ២០០.០០០នាក់ ជាកម្មករ កម្មការិនីរោងចក្រ

[១៧] តាមតួលេខប៉ាន់ស្មានរបស់ខុមហ្វ្រែល។

សំលៀកបំពាក់ ។ ទោះយ៉ាងណាក៏ដោយ ភាពមន្ទិលនេះបានបង្កើតជាចំណោទថែមទៀតចំពោះការប្រឹងប្រែងរបស់រាជរដ្ឋាភិបាល ទៅលើវិស័យអនិកម្មភាពរបស់ក្រុមជនពាក់ព័ន្ធ ក៏ដូចជាក្នុងចំណោមប្រជាពលរដ្ឋកម្ពុជាសកម្មទាំងមូល ពិសេសក្រុមចំណូលថ្មីទៅក្នុងទីផ្សារការងារដែលមានចំនួនរាយការណ៍ថ្មីៗនេះកើនឡើងដល់៣២ម៉ឺននាក់ក្នុងមួយឆ្នាំៗ ។

ចំណុចតែមួយគត់ ដែលសម្រេចបានដោយរាជរដ្ឋាភិបាល គឺការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈដាច់ដោយឡែកមួយនៅថ្ងៃទី៣ ធ្នូ ២០០៤ ។ ទោះបីយ៉ាងណាក៏ដោយ អ្នកវិភាគខ្លះបានមើលឃើញថា ការបង្កើតក្រសួងនេះ គឺដើម្បីបង្កើតការងារ និងផលប្រយោជន៍អ្នកនយោបាយក៏ដូចជាគណបក្សនយោបាយតែប៉ុណ្ណោះ ។ម្យ៉ាងទៀតព្រោះថាកន្លងមកគេមិនដឹងថាតើក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងសង្គមកិច្ចនិងការងារបានកំពុងធ្វើអ្វីខ្លះ? **គេមិនត្រូវបម្រុងថវិកាក្នុងការបង្កើតក្រសួង និងការិយាល័យសំរាប់អ្នកនយោបាយដ៏ច្រើន ក៏ដូចជាការបង្កើនកម្រាស់ការិយាធិបតេយ្យឡើយ ប៉ុន្តែគប្បីវិនិយោគជាក់ស្តែងក្នុងវិស័យការងារ ។**

ភាពមិនប្រាកដប្រជានោះក៏គួរនិយាយផងដែរអំពីការកំណត់លក្ខខណ្ឌចំណូលត្រឹមត្រូវមួយសំរាប់អ្នកមានការងារ បើទោះបីមានច្បាប់ការងារហើយក៏ដោយ ។ កម្មវិធីនយោបាយនេះ គឺបង្កើតការងារសំរាប់អ្នកអត់ការងារធ្វើ ដែលមានរបាយការណ៍ផ្លូវការបង្ហាញថាតែជាង៥%ប៉ុណ្ណោះ ។ ប៉ុន្តែបើយើងពិនិត្យឱ្យស៊ីជំរៅ គឺការបង្កើតការងារថ្មីឬរៀបចំលក្ខខណ្ឌ ឬការផ្លាស់ប្តូរការងារថ្មីៗសំរាប់អ្នកដែលមានការងារនោះក៏ជាការសំខាន់ដែរ ព្រោះថា កម្លាំងពលកម្មភាគច្រើនស្ថិតក្នុងវិស័យកសិកម្ម ដែលមានចំនួន ៧១,៤% នៃកម្លាំងពលកម្មសរុបចំនួនជាង៧លាននាក់ ហើយបុគ្គលិកមន្ត្រីរាជការ មានប្រមាណ ២០០.០០០ ឬ ៣០០.០០០នាក់ ដែលភាគច្រើនអ្នកទាំងនោះទទួលបានចំណូលមានកម្រិតស្ទើរនៅក្រោមបន្ទាត់នៃភាពក្រីក្រ ពោលគឺ ១ ដុល្លារអាមេរិក ក្នុង១ថ្ងៃ ។

ចំណុចទី៦៣ នៃកម្មវិធីនយោបាយគ្រាន់តែបានចែងថា *"ជំរុញអនុវត្តគោលនយោបាយជាប្រព័ន្ធ និងជាខ្សែសង្វាក់សំដៅបង្កើតការងារឱ្យបានច្រើនជូនដល់ស្រទាប់យុវវ័យដែលត្រូវដល់អាយុឈានចូលទីផ្សារពលកម្ម..."* **ប៉ុន្តែគេមិនដឹងថាតើរាជរដ្ឋាភិបាលមានគោលនយោបាយអ្វីខ្លះ ចំពោះយុវជនអត់ការងារធ្វើជាច្រើនរៀងរាល់ឆ្នាំ** ដែលក្នុងនោះនិស្សិតទើបបញ្ចប់ការសិក្សាមានចំនួន ៤៣.០០០ នាក់ក្នុងមួយឆ្នាំ ។ **ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលបែរជាចង់ធ្វើច្បាប់កាតព្វកិច្ចយោធាសម្រាប់យុវជនទៅវិញ ដោយមិនមានបញ្ជាក់ថាតើយុវជន ដែលចូលបំពេញកាតព្វកិច្ចយោធាហើយនោះនឹងអាចក្លាយជាពលករមានសមត្ថភាពចូលទៅក្នុងទីផ្សារពលកម្មដែរឬទេ?**

មានការសិក្សាថ្មីដោយធនាគារពិភពលោក ធនាគារអភិវឌ្ឍន៍អាស៊ី និងស្ថាប័នឯករាជ្យមួយចំនួន បានរកឃើញថា កម្ពុជាកំពុងតែប្រឈមមុខនឹងការមិនប្រសើរឡើងនៃបរិយាកាសវិនិយោគឯកជន ពិសេសវិស័យសហគ្រាសធុនតូច និងមធ្យម ដែលជាអ្នកអាចបង្កើតការងារដ៏ច្រើន។ បរិយាកាសមិនល្អនេះបានទប់ស្កាត់ការកើនឡើងសហគ្រាសខ្នាតតូច និងមធ្យមនោះ ជាសំខាន់បណ្តាលមកពីអំពើពុករលួយ និងភាពមិនប្រក្រតីនៃប្រព័ន្ធច្បាប់ និងតុលាការ ។ របាយការណ៍ ៦ ខែកន្លងមកនេះរកឃើញថា មានចំនួនវិនិយោគថ្មីៗតិចតួច និងមានភាពមិនទៀតទាត់ ដើម្បីឆ្លើយតបបាននឹងទីផ្សារការងារដែលកើនឡើងឥតឈប់ឈរនោះឡើយ ។ជាការពិតក្នុងវិស័យសាធារណៈ នយោបាយសេដ្ឋកិច្ចរបស់រាជរដ្ឋាភិបាល

បច្ចុប្បន្ន មិនសូវយកចិត្តទុកដាក់ឱ្យមានតុល្យភាពមួយក្នុងការបង្កើនវិនិយោគសាធារណៈដើម្បីបង្កើតការងារនោះទេ ប៉ុន្តែភាគច្រើនយកចិត្តទុកដាក់ចំពោះគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច ដោយទប់ស្កាត់អតិផរណានៃលុយរៀលច្រើនទៅវិញ។

នៅក្នុងចំណុចទី៦៣នេះ រាជរដ្ឋាភិបាលក៏បានសន្យាផងដែរថា: រាជរដ្ឋាភិបាល *"បង្កើតបណ្តាញបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈជូនជនក្រីក្រ ដែលផ្សារភ្ជាប់ជាមួយនឹងមជ្ឈមណ្ឌលពលកម្ម ព្រមទាំងការរៀបចំប្រព័ន្ធស្ថិតិការងារជាដើម។"* ចំណុចនេះ នៅជាផែនការលើក្រដាសរបស់រាជរដ្ឋាភិបាលនៅឡើយសម្រាប់រយៈពេលកន្លងមកនេះ ប៉ុន្តែមានការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈដូចនេះត្រូវបានប្រតិបត្តិដោយអង្គការសមាគមមិនមែនរដ្ឋាភិបាលភាគច្រើនទៅវិញ។ គេសង្ឃឹមថាក្រសួងការងារថ្មី នឹងអនុវត្តកម្មវិធីនយោបាយនេះ ប៉ុន្តែក្រសួងនឹងប្រាកដជាលើកបញ្ហាសំអាងរបស់ខ្លួនថាទើបបង្កើតថ្មី ឬគ្មានធនធានថវិកាគ្រប់គ្រាន់ព្រោះថវិកាជាតិ ដែលបម្រុងសំរាប់ក្រសួងនេះមានតិចតួចណាស់ គឺសំរាប់តែចំណាយចរន្តតែប៉ុណ្ណោះ។

ចំណែកឯ *"ការយកចិត្តទុកដាក់ទៅលើការពង្រឹងការគ្រប់គ្រងពលករបរទេសនៅកម្ពុជា ក្នុងទិសដៅដោះស្រាយការងារធ្វើជូនប្រជាពលរដ្ឋផង ក៏ដូចជាធ្វើការត្រួតពិនិត្យតាមដានពលករខ្មែរ ដែលនាំចេញទៅក្រៅប្រទេស"* ក៏នៅមានចំណុចខ្វះខាតច្រើនផងដែរ ដោយកន្លងមកការអនុវត្តន៍ច្បាប់អន្តោប្រវេសន៍ដើម្បីគ្រប់គ្រងជនបរទេសនៅកម្ពុជា មិនទាន់ត្រូវបានជំរុញជាយន្តការអនុវត្តន៍នៅឡើយ និងគ្មានការគ្រប់គ្រងច្បាស់លាស់ សូម្បីចំនួនអន្តោប្រវេសន៍ក៏គ្មានតួលេខច្បាស់ឡើយ។ ពលករបរទេសពីប្រទេសជិតខាង ដូចជាពីប្រទេសវៀតណាម និងចិនបាននិងកំពុងដណ្តើម ការងារសំណង់ និងរោងចក្រមួយចំនួន។ ចំណែកការត្រួតពិនិត្យតាមដានពលករខ្មែរដែលនាំចេញទៅក្រៅប្រទេស គឺមិនមានលក្ខណៈច្បាស់លាស់ ដែលមកដល់បច្ចុប្បន្នមានករណីជាច្រើនរាយការណ៍អំពីពលករខ្មែរត្រូវបានគេកេងប្រវ័ញ្ច និងបោកបញ្ឆោត ហើយដែលការជួយអន្តរាគមន៍ពីរាជរដ្ឋាភិបាល និងស្ថានទូតខ្មែរនៅប្រទេសទាំងនោះនៅមានកម្រិតយ៉ាងខ្លាំង។ **អបអរសាទររាជរដ្ឋាភិបាលដែលខិតខំជំរុញការនាំចេញកម្លាំងពលកម្មទៅក្រៅប្រទេសបន្ថែមទៀត** ដោយសមស្របត្រឹមត្រូវ និងមានការធានាក្នុងគោលដៅសម្រួលទីផ្សារការងារមួយផ្នែក និងមានលទ្ធភាពចាប់យកបច្ចេកវិទ្យាថ្មីៗតាមលទ្ធភាព។

ជារួម នៅមានកិច្ចការជាច្រើនដែលរាជរដ្ឋាភិបាលបានសន្យាជាគោលនយោបាយនៅក្នុងការបង្កើនការងារ ហើយប្រឈមមុខដ៏ខ្លាំងនិងមានភាពមិនប្រាកដប្រជាក្នុងការអនុវត្តន៍ រួមទាំងភាពខ្វះខាតការគ្រប់គ្រងចាត់ចែងរៀបចំគ្រប់គ្រងធនធានមនុស្សមានស្រេចនេះនៅឡើយ។

## ១០. វិស័យកសិកម្ម

ដោយពិនិត្យមើលទៅលើគោលនយោបាយសេដ្ឋកិច្ចតាមផ្នែកនៃវិស័យកសិកម្ម នៅក្នុងកម្មវិធីនយោបាយ ៧៣ ចំណុច គេសង្កេតឃើញថា រាជរដ្ឋាភិបាលបានដាក់ចេញទាំងការងារដែលត្រូវបន្តកាលពីអាណត្តិកន្លងទៅ និងការងារថ្មីមួយចំនួនបន្ថែមទៀត។ ហើយទន្ទឹមនឹងនោះ ក៏មានចំណុចមួយចំនួននៅក្នុងនោះត្រូវបានកែប្រែ ឬមិនមានចែងច្បាស់លាស់សមស្របតាមសកម្មភាពអនុវត្តឡើយ។

ចំណុចទី៣៥ ចែងថា *"រាជរដ្ឋាភិបាលនឹងបង្កើនការប្រើប្រាស់ធនធានក្នុងស្រុកសំរាប់អនុវត្តពហុវប្បកម្ម និងប្រពល-វប្បកម្ម កសិកម្ម ដើម្បីធានាបាននូវនិរន្តរភាពនៃកំណើនសកម្មភាពសេដ្ឋកិច្ច បង្កើតការងារ និងបង្កើនប្រាក់ចំណូលនៅ*

*ជនបទ"។* ជាការពិតចំណុច នេះមិនមែនជារឿងថ្មីទេ ព្រោះរាជរដ្ឋាភិបាលអាណត្តិមុនបានដាក់ផែនការ ហើយបានកំពុងអនុវត្តដោយពុំទាន់ចំចំណុចសំខាន់ៗ។ **រាជរដ្ឋាភិបាលមិនមានដំណោះស្រាយបញ្ហានៃការបង្កើនគៀងគរធនធានក្នុងស្រុកឱ្យមានប្រសិទ្ធភាពឡើយ តួយ៉ាងដំណោះស្រាយសំខាន់ពាក់ព័ន្ធមួយ គឺការកែទម្រង់គ្រប់គ្រងដីធ្លី។** តាមការវាយតម្លៃដោយរបាយការណ៍នៃវិទ្យាស្ថានសេដ្ឋកិច្ចកម្ពុជាឱ្យដឹងថា: *"ជារួម កត្តាផ្ទៃដីដាំដុះនេះមានសក្តានុពលសំរាប់ការពង្រីកវិស័យកសិកម្ម ជាពិសេសចំពោះដំណាំឧស្សាហកម្មដែលផ្តល់តម្លៃបន្ថែមខ្ពស់ (value-added crops) ប៉ុន្តែ ផ្ទៃដីទាំងនោះត្រូវបានគ្រប់គ្រងជាលក្ខណៈឯកជនដោយភាគច្រើន និងមានតម្លៃខ្ពស់ ដែលជាហេតុនៃឧបសគ្គដល់ការវិនិយោគលើវិស័យកសិកម្មនេះ[១៨]។"* ហើយជា លក្ខណៈបច្ចេកទេសផ្ទៃដីប្រមាណ ៧៥% នៃផ្ទៃដីសរុបស្ថិតនៅក្រោមការគ្រប់គ្រងរបស់រដ្ឋ ហើយផ្ទៃដីដែលអាចដាំដុះបាន សំរាប់ប្រជាពលរដ្ឋខ្មែរម្នាក់ៗ មានជាមធ្យមគឺត្រឹមតែ ០,២៧ ហិកតាប៉ុណ្ណោះ។ មួយវិញទៀត គោលនយោបាយសម្បទានដីក៏មិនបានធ្វើឱ្យការអភិវឌ្ឍកសិកម្មប្រសើរឡើយ ដោយសារតែសម្បទានមួយចំនួនអសកម្ម និងថែមទាំងបង្កើតបាតុភាពជំលោះដីធ្លីជាមួយប្រជាពលរដ្ឋតាមមូលដ្ឋានជាញឹកញាប់ទៀតផង យោងតាមរបាយការណ៍ជាបន្តបន្ទាប់ រាប់តាំងពីរបស់អង្គការមិនមែនរដ្ឋាភិបាលថ្នាក់ជាតិ (សមាគមអាដហុក[១៩]: *"វិវាទដីធ្លីបានកើនឡើងយ៉ាងច្រើនដែលធ្វើឱ្យប៉ះពាល់យ៉ាងខ្លាំងទៅដល់សិទ្ធិមានដីធ្លីរបស់ប្រជាជនក្រីក្រនិងគ្មានអំណាច"*) រហូតដល់របាយ-ការណ៍ របស់តំណាងពិសេសរបស់លោកអគ្គលេខាធិការអង្គការសហប្រជាជាតិ (លោក Peter Leuprecht: *"អ្នកទទួលបានសម្បទានជាញឹកញាប់មានការគិតគូរតិចតួចចំពោះប្រយោជន៍ សិទ្ធិ និងសុខមាលភាពរបស់ប្រជាពលរដ្ឋមូលដ្ឋានដែលរងការប៉ះពាល់។ ការគ្រប់គ្រងសម្បទាននាំឱ្យមានការដកហូតសិទ្ធិ និងភាពក្រីក្រដល់ប្រជាពលរដ្ឋមូលដ្ឋាន ថែមទាំងបង្កើនជម្លោះ...។"*)

ចំណុចទី៣៥បានបញ្ជាក់អំពី *"ការធានាសន្តិសុខស្បៀងសំរាប់ប្រជាពលរដ្ឋទូទៅ"*។ សម្តេច នាយករដ្ឋមន្ត្រី ហ៊ុន សែន ធ្លាប់មានប្រសាសន៍យ៉ាងមាំទាំថា *"រាជរដ្ឋាភិបាលនឹងមិនបណ្តោយឱ្យប្រជាពលរដ្ឋខ្មែរណាម្នាក់ស្លាប់[រងគ្រោះ] ដោយភាពអត់ឃ្លាននោះឡើយ។"* ប៉ុន្តែ ជាក់ស្តែងការសន្យាទាំងលើក្រដាសផែនការ និងយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រមិនទាន់បានអនុវត្តមានប្រសិទ្ធភាព ដោយកម្រិតប្រជាពលរដ្ឋរស់នៅក្រោមបន្ទាត់នៃភាពក្រីក្រនៅក្រោម **ឬស្មើនឹង ១ ដុល្លារអាមេរិកដែលប៉ះពាល់ដល់សន្តិសុខស្បៀងជាទូទៅមានកម្រិតខ្ពស់ដដែលចំនួន ៣៦% និងអាចកើនឡើងទៀតផង។**

**សកម្មភាពដោះស្រាយសន្តិសុខស្បៀងសំរាប់ប្រជាពលរដ្ឋនោះ គឺនៅត្រឹមតែវិធានការប្រតិកម្ម** (reactive) ដូចជា ចុះចែកអំណោយបន្តិចបន្តួច ឬចាក់ផ្សាយតាមទូរទស្សន៍ការផ្តល់អំណោយដល់ជនទុរគតមួយចំនួនតូចតែប៉ុណ្ណោះ។ ហើយមកដល់ពេលនេះ គេមិនដឹងថាតើរាជរដ្ឋាភិបាលបានដោះស្រាយបញ្ហាស្បៀងជាមួយកម្មវិធីស្បៀងពិភពលោក (WFP) យ៉ាងណានៅឡើយ។ នៅប៉ុន្មានថ្ងៃមុននេះ មានការរាយការណ៍ថា ប្រជាជននៅស្រុកគងពិសី ខេត្តកំពង់ស្ពឺចំនួន ១០ ទៅ២០% ស្មើនឹងជាង ២.០០០ គ្រួសារកំពុងជួបគ្រោះអត់ឃ្លានធ្ងន់ធ្ងរ ហើយប្រជាពលរដ្ឋខ្លះបន្ថយអាហារ និងបរិភោគទឹកដើម្បីចំអែត។

---

[១៨] Sok Hach, *"Cambodia Economic Watch"*, Economic Institute of Cambodia, October 2004.

[១៩] សមាគមអាដហុក: *"ស្ថានភាពសិទ្ធិមនុស្ស ២០០៤"* មករា ២០០៥។

ជាការពិត រាជរដ្ឋាភិបាលបានកំពុងអនុវត្តចំណុចទី៣៦ខ្លះ ពោលគឺរាជរដ្ឋាភិបាលមិនយកពន្ធលើដីធ្លីកសិកម្មរបស់កសិករ។ ទោះបីយ៉ាងណា ក្នុងការយកលេសប្រើប្រាស់គោលនយោបាយ រាជរដ្ឋាភិបាលមិនបានអនុវត្តច្បាប់ភូមិបាលដែលបានអនុម័តតាំងពីឆ្នាំ២០០១ ក្នុងការប្រមូលពន្ធលើអ្នកទិញដីរាប់ពាន់ម៉ឺនហិកតាទុកចោលទំនេរដោយឈ្មួញ និងមន្ត្រីមានអំណាចធំៗ។ ចំណុចទី៣៦ចែងថាៈ *"រាជរដ្ឋាភិបាលនឹងជំរុញបរិយាកាសល្អសំរាប់ការចូលរួមរបស់ផ្នែកឯកជន ដើម្បីការលូតលាស់នៃវិស័យកសិកម្ម តាមរយៈការប្រឹងប្រែងពន្លឿនការផ្តល់កម្មសិទ្ធិដីធ្លីនៅតាមតំបន់ជនបទ... ការអភិវឌ្ឍប្រព័ន្ធស្រោចស្រពផ្ទៃដី និងការគ្រប់គ្រងធនធានទឹក... បង្កើនប្រសិទ្ធភាពក្នុងការប្រើប្រាស់ប្រព័ន្ធធារាសាស្ត្រដែលមានស្រាប់។"* ការផ្តល់កម្មសិទ្ធិដីធ្លីនេះកំពុងតែត្រូវបានអនុវត្តក្នុងចំនួន ២០.០០០ កម្មសិទ្ធិក្នុងមួយខែ នៅឆ្នាំកន្លងមក ហើយសង្ឃឹមថាកើនឡើងដល់ចំនួន ៣០.០០០ ក្នុងមួយខែ នៅឆ្នាំ២០០៥នេះ[២០]។ **យ៉ាងណាក៏ដោយ ល្បឿននៃការចុះបញ្ជីនេះត្រូវបានវាយតម្លៃថាមានលក្ខណៈយឺតយ៉ាវ ហើយដំណើរការផ្តល់កម្មសិទ្ធិដីធ្លីជារួមមិនរលូន ថែមទាំងមានភាពមិនប្រក្រតីមួយចំនួន។** លោក ម៉ិច សុខន នាយករងអង្គការវីជីឡែន (Vigilance) អ្នកសង្កេតការណ៍លើការងារផ្តល់កម្មសិទ្ធិបានឱ្យដឹងថាៈ *"ទន្ទឹមនឹងដំណើរការចុះកម្មសិទ្ធិដីធ្លីនេះមិនរលូនមានភាពមិនប្រក្រតីមួយចំនួនក្នុងការយកលុយកាក់ពីប្រជាពលរដ្ឋ បញ្ហាជម្លោះដីធ្លីបានកើតឡើងជាញឹកញាប់ ពិសេសដោយមានជនឆ្លៀតឱកាសចាប់យកដីធ្លីតំបន់នោះដែលត្រូវបានប្រកាសចុះបញ្ជីធ្វើកម្មសិទ្ធិ ហើយកន្លងមកក្រសួងមានសមត្ថកិច្ចមិនមានវិធានការណ៍ដោះស្រាយមានប្រសិទ្ធភាពឡើយ"*។ ហើយបាតុភាពនេះ អាចនាំឱ្យមានភាពមិនច្បាស់លាស់ ក្នុងការអនុវត្តភាពអនុគ្រោះផ្នែកពន្ធទៅលើដីធ្លីបែបវិនិយោគទុនដីដែលទុកទំនេរចោល និងដីធ្លីកសិកម្មរបស់កសិករជាលក្ខណៈគ្រួសារដែលត្រូវទទួលបានការអនុគ្រោះមិនយកពន្ធ។

ចំពោះបញ្ហាធារាសាស្ត្រ ប្រមុខរដ្ឋាភិបាលថែមទាំងបានប្រកាសថា រដ្ឋាភិបាលអាណត្តិទី៣នេះជា *"រាជរដ្ឋាភិបាលធារាសាស្ត្រ"*។ **ប៉ុន្តែដោយឡែក គេឃើញមានខ្ទង់ចំណាយថវិកាជាតិច្បាស់លាស់នៅក្នុងការគ្រប់គ្រងហិរញ្ញវត្ថុឆ្នាំ២០០៥ សំរាប់ការងារស្ថាបនាប្រព័ន្ធធារាសាស្ត្រនេះតិចតួចបំផុតដូចអាណត្តិកន្លងមក ហើយក៏ពុំទាន់មានផែនការជាក់លាក់ អំពីធារាសាស្ត្រនេះទេ។ ថ្មីៗនេះ គេឃើញមន្ត្រីជាន់ខ្ពស់នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុទៅពិនិត្យចាត់ចែងគម្រោងការសាងសង់ធារាសាស្ត្រតាមអនុសាសន៍របស់នាយករដ្ឋមន្ត្រីទៅវិញ ដូច្នេះដោយឡែកគេមានមន្ទិលទៅលើការងាររបស់ក្រសួងធនធានទឹកថាតើកំពុងធ្វើអ្វី?**

ចំណុចទី ៣៧ ៣៨ និង ៣៩ នៃកម្មវិធីនយោបាយ ៧៣ចំណុច អំពីការផ្តល់សេវាកម្មដល់វិស័យកសិកម្មជាតិបានបង្ហាញនូវចំណុចសំខាន់ៗជាច្រើន ដែលរដ្ឋាភិបាលត្រូវសំរេចឱ្យបានជាចាំបាច់នៅពេលដែលស្ថានភាពជាទូទៅលើវិស័យនេះនៅមានភាពទន់ខ្សោយ ហើយប្រជាកសិករមិនធ្លាប់ត្រូវបានផ្គត់ផ្គង់ជាឧបត្ថម្ភធន (subsidies) និងអន្តរាគមន៍ជាគម្រោងការ ដែលមានលក្ខណៈជាក់លាក់នៅឡើយ។ ការបំពេញការសន្យាតាមចំណុចខាងលើនេះនឹងបានជាប្រយោជន៍ផ្ទាល់ដល់កសិករ។ ប៉ុន្តែជាថ្មីម្តងទៀត **នៅក្នុងរយៈពេលមួយឆមាសកន្លងមកនេះ សកម្មភាពរបស់រាជរដ្ឋាភិបាលទទួលបានជាលទ្ធផលតិចតួចប៉ុណ្ណោះនៅក្នុងការអនុវត្តចំណុចនៃកម្មវិធីនយោបាយ ដែលមានដូចជាៈ**

[២០] Peter Leuprecht, *"Land concessions for economic purposes in Cambodia, A human rights perspective"*, COHCHR, November 2004.

ដោយសន្យាពង្រីកសេវាកម្មសំរាប់វិស័យកសិកម្មចំណុចទី៣៧ មានទិសដៅជំរុញផលិតភាពកសិកម្ម *"ដោយពង្រីកការងារស្រាវជ្រាវ និងផ្សព្វផ្សាយ ការអភិវឌ្ឍទីផ្សារកសិកម្ម ការបែងចែកសំភារៈពូជ ជី និងការផ្តល់ឥណទានជនបទដោយមានអត្រាការប្រាក់ទាប..."* ប៉ុន្តែ គេសង្កេតឃើញថា **ការស្រាវជ្រាវ និងផ្សព្វផ្សាយនេះមិនមានសកម្មភាពគួរឱ្យចាប់អារម្មណ៍ទេ** ដោយគ្រាន់តែបន្តមកពីអាណត្តិមុនមកជាធម្មតា។ ចំពោះ *"ការអភិវឌ្ឍទីផ្សារកសិកម្ម"* វិញឃើញថា រាជរដ្ឋាភិបាលបានជោគជ័យក្នុងការនាំប្រទេសកម្ពុជាចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក (WTO) ដែលមានសក្តានុពលទីផ្សារថ្មី និងធំដូចជា ទីផ្សារចិន ជប៉ុន និងកូរេជាដើម សំរាប់ផលិតផលកសិកម្មរបស់ប្រទេសកម្ពុជា។ ទោះបីយ៉ាងនេះក្តី រាជរដ្ឋាភិបាលមិនទាន់បានដោះស្រាយកង្វល់របស់អង្គការមិនមែនរដ្ឋាភិបាលដែលថា: *"កសិករកម្ពុជាគ្មានលក្ខណៈប្រកួតប្រជែងទេ ព្រោះពួកគេមានលទ្ធភាពតិចតួចក្នុងការទទួលបានបច្ចេកវិទ្យា គ្រាប់ពូជ ប្រព័ន្ធធារាសាស្ត្រ និងឧបករណ៍ផ្សេងៗទៀត។...ពួកគេនៅមិនទាន់មានការរៀបចំល្អនៅឡើយទេ។ការចូលរបស់កម្ពុជាទៅក្នុងអង្គការពាណិជ្ជកម្មពិភពលោកនឹងរឹតតែធ្វើឱ្យស្ថានភាពនេះកាន់តែអាក្រក់ទៅ ប្រសិនបើគ្មានយន្តការសមស្របសំរាប់លើកកំពស់សមត្ថភាពកសិកម្មក្នុងស្រុក ដើម្បីដោះស្រាយដោយជោគជ័យជាមួយពាណិជ្ជកម្មសេរីទេនោះ[២១]។"* **រាជរដ្ឋាភិបាលត្រូវតែធ្វើការកត់សម្គាល់ថា ប្រទេសអ្នកមានស្ទើរទាំងអស់ដែលជាសមាជិក WTO គឺបានកំពុងផ្តល់ឧបត្ថម្ភធនយ៉ាងច្រើនទៅលើវិស័យកសិកម្មរបស់គេ។**

ចំណុចទី៣៧ដដែលបានរៀបរាប់អំពី *"ការបែងចែកសំភារៈ ពូជ ជី"* នោះគឺនៅមានលទ្ធភាពតិចតួចដូចពោលខាងលើនេះ ដូច្នេះនាំឱ្យមានការពឹងផ្អែកយ៉ាងខ្លាំងលើទំនិញនាំចូល ជាពិសេសការចំណាយលើជី និងថ្នាំសំលាប់សត្វល្អិតដែលមានការរកឃើញថា: *"យ៉ាងហោចណាស់ទឹកប្រាក់ប្រមាណជា ៥០ លានដុល្លារត្រូវបានចំណាយដើម្បីទិញទំនិញទាំងនេះក្នុងមួយឆ្នាំៗ[២២]។"* បើនិយាយអំពី *"ការផ្តល់ឥណទានជនបទជាមួយនឹងការប្រាក់ទាប"* គឺក៏នៅមិនទាន់បានអនុវត្តជាប្រព័ន្ធមាននិរន្តរ៍ភាពឡើយ។ ជាក់ស្តែងអត្រាការប្រាក់តាមការផ្តល់ឥណទានដោយស្ថាប័នហិរញ្ញវត្ថុមួយចំនួនដែលប្រជាជនតាមមូលដ្ឋានអាចប្រើប្រាស់បាន តួយ៉ាងធនាគារអេស៊ីលីដាជាដើម មិនមានការថយចុះ ពោលគឺជាមធ្យមអត្រាការប្រាក់មានចំនួន៥៤%ក្នុងមួយឆ្នាំដដែល ដោយថ្មីៗនេះគ្រាន់តែមានការកាត់បន្ថយសំណុំបែបបទសំរាប់កម្ចីខ្លះក្នុងគោលដៅពង្រីកឥណទានបន្ថែមប៉ុណ្ណោះ។

ចំណុចបន្តទៀតនៅចំណុចទី ៣៧ នេះដដែលស្តីពី *"ការរំលែកតួនាទីជាជំហានៗ ទៅឱ្យក្រុមប្រឹក្សាឃុំ/សង្កាត់ [ផ្អែកលើមូលដ្ឋាននៃការអនុវត្តន៍គោលនយោបាយវិមជ្ឈការ] ដែលនឹងទទួលបាននូវការពង្រឹងសមត្ថភាពឱ្យក្លាយទៅជាអាជ្ញាធរអភិវឌ្ឍន៍ ជាអ្នកផ្ទេរចំណេះដឹងនិងចំណេះធ្វើជូនកសិករនៅតាមមូលដ្ឋាន..."* នៅជួបប្រទះបញ្ហាជាច្រើនដូចដែលរបាយការណ៍ស្តីពីសកម្មភាពការងារឆ្នាំ២០០៤ និងទិសដៅភារកិច្ចត្រូវអនុវត្តបន្តរបស់នាយកដ្ឋានរដ្ឋបាលមូលដ្ឋានក្រសួងមហាផ្ទៃបានលើកឡើងថា: *"...ចំណុចគួរកត់សំគាល់គឺមានគម្រោងអភិវឌ្ឍន៍របស់ឃុំ/សង្កាត់មួយចំនួនមិនបានផ្តើមចេញពី*

---

[២១] *"កសិកម្ម និង ការអភិវឌ្ឍជនបទ"* នៅក្នុង

សេចក្តីថ្លែងការណ៍របស់អង្គការមិនមែនរដ្ឋាភិបាលចំពោះកិច្ចប្រជុំក្រុមពិគ្រោះយោបល់ស្តីពីកម្ពុជាឆ្នាំ២០០៤។

[២២] សូមមើល : *"កសិកម្ម និង ការអភិវឌ្ឍជនបទ"* ដដែល។

*សំណូមពររបស់ប្រជាពលរដ្ឋ ដែលជាហេតុបង្កឱ្យមានការថ្នាំងថ្នាក់ពីសំណាក់ប្រជាជន និងមានការលំបាកនៅពេលអនុវត្តគម្រោង[២៣]។"* ជាទូទៅគេមើលឃើញថា វិមជ្ឈការឃុំ/សង្កាត់នៅកម្ពុជា រហូតមកដល់ពេលនេះស្ថិតនៅដំណាក់កាលពង្រឹងសមត្ថភាពឃុំ/សង្កាត់ខ្លួនឯងតែប៉ុណ្ណោះ ហើយវាជាដំណាក់កាលរយៈពេលយូរអង្វែង។

*"ការបង្កើតសាលាបច្ចេកទេសកសិកម្មនៅតាមខេត្តមួយចំនួន និងបង្កើតមជ្ឈមណ្ឌលអភិវឌ្ឍន៍កសិកម្ម និងកសិដ្ឋានគំរូនៅតាមស្រុកមួយចំនួន"* ក្នុងរយៈពេល ៦ ខែ កន្លងមកនេះ មិនឃើញមានឡើយ។ ហើយការសន្យានៅក្នុងកម្មវិធីនយោបាយថាខិតខំៈ *"បង្ហាញផ្សព្វផ្សាយ និងបណ្តុះបណ្តាលជូនកសិករអំពីបច្ចេកទេសកសិកម្ម..."* គឺពុំទាន់ដំណើរការធំដុំខុសពីធម្មតានោះទេ។ *"ទិន្នផលខ្ពស់អំពីការធ្វើកសិដ្ឋានចំរុះ និងអំពីព័ត៌មានទីផ្សារ..."* នៅមានភាពទន់ខ្សោយយ៉ាងខ្លាំងក្នុងការផ្តល់លទ្ធភាពឱ្យកសិករបង្កើនផលិតភាព កុំថាឡើយដើម្បី *"ឆ្លើយតបទៅនឹងការតម្រូវនៃស្តង់ដារអន្តរជាតិ"* ដែលកសិករភាគច្រើនមិនទាន់បានយល់ដឹងអំពីស្តង់ដារនោះយ៉ាងម៉េចនៅឡើយ។ មានការព្រួយបារម្ភផងដែរអំពីការតម្រូវឱ្យមាន"ស្តង់ដារអន្តរជាតិ"នេះថានឹងអាចត្រូវបានប្រើប្រាស់ជាឧបសគ្គពីសំណាក់អាជ្ញាធរពាក់ព័ន្ធដែលនឹងដាក់កំហិតតឹងតែងលើផលិតកម្មកសិកម្មក្នុងស្រុក និងបង្កឱ្យមានការបង្កើនតម្លៃផលិតផលកសិកម្ម។ នៅខណៈពេលដែលសន្តិសុខស្បៀងមិនទាន់ត្រូវបានធានានៅឡើយនេះ គេគួរសិក្សាផលប៉ះពាល់នៃបញ្ហានេះឱ្យបានច្បាស់ជាមុន ថាតើការតម្រូវឱ្យមានស្តង់ដារអន្តរជាតិលើផលិតកម្មកសិកម្មនេះនឹងជាវិធានច្បាប់សំរាប់គាំទ្រការនាំចេញ ឬរាជរដ្ឋាភិបាលគ្រាន់តែខិតខំជំរុញឱ្យមានការប្រកួតប្រជែងដោយសេរី និងយុត្តិធម៌រវាងផលិតករ ហើយឈានទៅរកស្តង់ដារមួយ ដោយរាជរដ្ឋាភិបាលធ្វើជាអ្នកសំរបសំរួល!

*"ការយកចិត្តទុកដាក់ជាពិសេសទៅលើការតំរង់ទិសកិច្ចការវិនិយោគសាធារណៈ និងការលើកទឹកចិត្តវិនិយោគឯកជន ឱ្យឆ្ពោះទៅរកវិស័យកសិកម្ម សំដៅលើកកំពស់កំណើនកសិផល..."* ឃើញមានការកំពុងអនុវត្តដោយឡែក១ពីរាជរដ្ឋាភិបាលខ្លះ១ហើយ ដោយអនុញ្ញាតឱ្យក្រុមហ៊ុនឯកជនធ្វើអាជីវកម្មលើដីជាច្រើនហិកតាដើម្បីដាំដុះដំណាំកសិ-ឧស្សាហកម្មដូចជានៅ ខេត្តកំពង់ស្ពឺ ពោធិ៍សាត់ ជាដើម។ ប៉ុន្តែយ៉ាងណាក៏ដោយ ទំនាស់ដីធ្លីរវាងក្រុមហ៊ុន និងប្រជាជននៅមូលដ្ឋានទីនោះក៏កើតមានជាបន្តបន្ទាប់ផងដែរ ជាក់ស្តែងដូចជាករណីទំនាស់ធ្ងន់ធ្ងររវាងក្រុមហ៊ុនភាពីម៉ិច ដែលទទួលសម្បទានពីរាជរដ្ឋាភិបាលរានដីដាំដើមអាកាសា និងប្រជាជននៅទីនោះ។ រាជរដ្ឋាភិបាលក៏ត្រូវពិចារណាឱ្យបានហ្មត់ចត់ថែមទៀតចំពោះការវិនិយោគលើដីទាំងឡាយណា ពិសេសដីដែលមានទ្រង់ទ្រាយធំ ដែលងាយប៉ះពាល់បរិស្ថាន។

នៅក្នុងវិស័យកសិកម្មនេះផងដែរ រាជរដ្ឋាភិបាលមិនទាន់តម្រង់ទិស និងពង្រីកនូវសកម្មភាពនៅក្នុងចំណុចទី៣៨នៃកម្មវិធីនយោបាយដែលថាៈ *"រាជរដ្ឋាភិបាលបន្តផ្តល់អាទិភាពទៅលើកិច្ចការអភិវឌ្ឍតំបន់ព្រំដែន និងតំបន់ជនបទដាច់ស្រយាល ដើម្បីទប់ស្កាត់ការធ្វើចំណាកចោលស្រុក តាមរយៈការរៀបចំ និងកសាងតំបន់ទីប្រជុំជនមួយចំនួន ដែលមានបណ្តាញហេដ្ឋារចនាសម្ព័ន្ធសមស្របជាពិសេសផ្លូវគមនាគមន៍ និងភូមិអភិវឌ្ឍន៍តាមបណ្តោយព្រំដែនសំរាប់សំរួលដល់ជីវភាពរស់នៅនិងការចូលរួមទៅក្នុងសកម្មភាពសេដ្ឋកិច្ចរបស់ប្រជាពលរដ្ឋនៅទីនោះ។"* រាជរដ្ឋាភិបាលបែរជាកំពុងជំរុញការបង្កើត

---

[២៣] *"របាយការណ៍ស្តីពី សកម្មភាពការងារ ឆ្នាំ២០០៤ និង ទិសដៅការកិច្ចត្រូវអនុវត្តបន្ត"* លេខ ១២៧ របករម នាយកដ្ឋានរដ្ឋបាលមូលដ្ឋាន អគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ ថ្ងៃទី ២ ធ្នូ ២០០៤។

ឡើងនូវមណ្ឌលបនល្បែងស៊ីសងជាច្រើននៅតាមតំបន់ព្រំដែន ទាំងខាងលិច និងខាងកើត ដែលប្រើប្រាស់កម្លាំងពលកម្មតិចតួច ហើយបង្កបាតុភាពសង្គមជាច្រើនយ៉ាងជំនួសឱ្យការអភិវឌ្ឍវិស័យកសិកម្មតាមការសន្យាខាងលើនេះ។ ការអនុវត្តកន្លងមកទាក់ទិនចំណុចនេះ គឺជាការមិនត្រឹមត្រូវ ព្រោះគេសង្កេតឃើញថា បញ្ហាព្រំដែនដែលត្រូវបានចោទប្រកាន់ថាមានការទន្ទ្រានយកដីព្រំប្រទល់ពីប្រជាពលរដ្ឋប្រទេសជិតខាងបានកំពុងបន្ត និងពុំទាន់ត្រូវបានដោះស្រាយ។ ប្រជាពលរដ្ឋជាពិសេសអ្នករស់នៅតាមតំបន់ព្រំដែនភាគច្រើន មិនមានជីវភាពប្រសើរឡើង ហើយបន្តធ្វើចំណាកចោលស្រុកទៅប្រទេសជិតខាងដោយខុសច្បាប់។

ចំពោះចំណុចទី ៣៩ ដែលរាជរដ្ឋាភិបាល *"បន្តជំរុញចលនាភូមិមួយ-ផលិតផលមួយ"* នោះវិញ ក្រៅពីធ្វើសិក្ខា-សាលាដែលមាននៅតែត្រឹមកម្រិតក្រសួងពាណិជ្ជកម្មក្រៅពីនោះ គឺមិនទាន់ឃើញមានសកម្មភាពណាមួយប្រាកដប្រជាជំរុញទស្សនាទាននេះឱ្យទៅជាផលប្រយោជន៍ប្រជាពលរដ្ឋជាក់ស្តែងនៅឡើយ។ តើមានកសិករប៉ុន្មាននាក់ដែលដឹងថាៈ "អ្វីទៅជាចលនាភូមិមួយ-ផលិតផលមួយ"?

## សន្និដ្ឋាន

របាយការណ៍សង្កេត ៦ ខែខាងលើពិតជាបង្ហាញថា រាជរដ្ឋាភិបាលពុំទាន់អនុវត្តសំរេចកម្មវិធីនយោបាយរបស់ខ្លួនលើ ១០ ចំណុចសំខាន់ៗនេះនៅឡើយ ដែលចំណុចទាំងនេះនឹងធ្វើឱ្យមានការមើលឃើញថា នឹងមានការប្រែប្រួលផ្លាស់ប្តូរខុសគ្នាពីអាណត្តិមុនៗ។ បើទោះបីជាការរកឃើញនៅក្នុងរបាយការណ៍ បានបង្ហាញពីបញ្ហាច្រើនជាងសមិទ្ធិផលក៏ដោយ ក៏របាយការណ៍នេះ គ្មានបំណងតិះទៀនរាជរដ្ឋាភិបាល ឬគណបក្សនយោបាយនានានៅក្នុងរាជរដ្ឋាភិបាលឡើយ ព្រោះថាមានរយៈពេលខ្លីត្រឹមតែ ៦ ខែប៉ុណ្ណោះ។ របាយការណ៍នេះ នឹងក្លាយជាកញ្ចក់ឆ្លុះបញ្ចាំងសម្រាប់រាជរដ្ឋាភិបាល និងគណបក្សនយោបាយធំៗ ហើយនិងជាព័ត៌មានដំបូងសំរាប់អ្នកបោះឆ្នោតផងដែរ។

*សូមអរគុណចំពោះការយកចិត្តទុកដាក់តាមដានរបស់លោកអ្នក។*

សំរាប់ព័ត៌មានផ្សេងៗសូមទាក់ទងមកស្នាក់ការកណ្តាលខុមហ្វ្រែល

ផ្ទះលេខ ១៣៨ ផ្លូវ ១២២ សង្កាត់ទឹកល្អក់ទី១ ខ័ណ្ឌទួលគោក រាជធានីភ្នំពេញ

ទូរស័ព្ទលេខៈ ០២៣ ៨៨៤ ១៥០ ទូរសារលេខៈ ០២៣ ៨៨៣ ៧៥០

អ៊ីម៉ែលៈ comfrel@online.com.kh គេហទំព័រៈ wwww.comfrel.org